# ព្រះរាជក្រម

នស/រកម/០៦០៦/០១៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់ឆ្លងដែន

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលធ្វើនៅទីក្រុងបាសែល ប្រទេសស្វីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកាលំនីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម/០៦០៦/០២៤ **ព្រះមហាក្សត្រ និងព្រះរាជបញ្ជាករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ... ខែមិថុនា ឆ្នាំ២០០៦

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់ឆ្លងដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែលស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលធ្វើនៅទីក្រុងបាសែល ប្រទេសស្វីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកាលនីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

នៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម/០៦០៦/០១៨ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខ: ៤៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ២០០៦

អគ្គលេខាធិការរងទទួលបន្ទុករដ្ឋបាល

ស៊ុំ ចិនគេង

# អត្ថបទ អនុសញ្ញាបាសែល
# ស្តីពី
# ការត្រួតពិនិត្យចលនាដឹកជញ្ជូន
# និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន

*Text of Basel Convention*
*on*
*the Control of Transboundary Movements*
*of Hazardous Wastes and Their disposal*

## មាត្រាទី ១
## វិសាលភាពរបស់អនុសញ្ញាអន្តរជាតិ " បាសែល "

១- គោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រធានបទនៃការដឹកជញ្ជូនសំណល់ឆ្លងដែន ដែលជាប្រភេទសំណល់គ្រោះថ្នាក់ ។

ក- ប្រភេទសំណល់ស្ថិតក្នុងឧបសម្ព័ន្ធទី I មិនត្រូវមានលក្ខណៈដូចសំណល់នៅក្នុងឧបសម្ព័ន្ធទី III ឡើយ ។

ខ- ប្រភេទសំណល់ដែលមិនស្ថិតក្នុងវាក្យខ័ណ្ឌ " ក " ប៉ុន្តែអាចកំណត់ ឬក៏អាចចាត់ទុកថាជាសំណល់គ្រោះថ្នាក់បាន ដោយយោងតាមច្បាប់នៃប្រទេសនិមួយៗរបស់ភាគី ដែលធ្វើការនាំចេញ នាំចូល និងធ្វើការដឹកជញ្ជូនឆ្លងកាត់ ។

២- "សំណល់ដទៃទៀត" ដែលជាគោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រភេទសំណល់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី II ។

៣- សំណល់ដែលមានជាតិវិទ្យុសកម្ម ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញាអន្តរជាតិ "បាសែល" ទេ ប៉ុន្តែវាជាភារកិច្ចត្រួតពិនិត្យរបស់ប្រព័ន្ធអង្គការអន្តរជាតិ ដែលមានច្បាប់អន្តរជាតិកំណត់ទៅលើសារធាតុវិទ្យុសកម្មដាច់ដោយឡែក ។

៤- ការបញ្ចេញសំណល់ពីការប្រើប្រាស់ធម្មតាតាមនាវា ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញានេះទេ ប៉ុន្តែវាស្ថិតក្រោមការត្រួតពិនិត្យរបស់ច្បាប់អន្តរជាតិផ្សេងៗទៀត ។

## មាត្រាទី ២
## និយមន័យ

១- "**សំណល់**" ជាសារធាតុ ឬវត្ថុទាំងឡាយណាដែលត្រូវបានបោះចោល ឬមានបំណងបោះចោល ឬត្រូវអោយបោះចោល ដោយអនុលោមតាមច្បាប់ជាតិរបស់ប្រទេសនិមួយៗ ។

២- "**ការគ្រប់គ្រង**" ជាការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត រួមទាំងការថែរក្សាទីលានចាក់សំណល់បន្ទាប់ពីធ្វើការចាក់ចោលរួចមក ។

៣- "**ការដឹកជញ្ជូនឆ្លងដែន**" ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ដែលតំបន់នោះស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ប្រទេសផ្សេងគ្នា យ៉ាងហោចណាស់ត្រូវពាក់ព័ន្ធនឹងច្បាប់ដឹកជញ្ជូននៃប្រទេសចំនួនពីរដែរ ។

៤- "**ការបោះបង់ចោល**" រាល់ដំណើការនៃការបោះបង់ចោលសំណល់ នឹងត្រូវបានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី IV នៃអនុសញ្ញាអន្តរជាតិ "បាសែល" នេះ ។

៥- "**ទីតាំងអនុញ្ញាត ឬមធ្យោបាយសំរាប់ទុកដាក់សំណល់**" គឺសំដៅលើទីកន្លែង ឬមធ្យោបាយសំរាប់ការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដែលត្រូវបានអនុញ្ញាតអោយដំណើរការសំរាប់

គោលបំណងខាងលើ តាមរយៈអាជ្ញាធរពាក់ព័ន្ធនៃប្រទេសដែលមានទីកន្លែង ឬមានមធ្យោបាយទុកដាក់សំណល់ ។

៦- " **អាជ្ញាធរមានសមត្ថកិច្ច** " ជាអាជ្ញាធររដ្ឋាភិបាលមួយ ដែលបានចាត់តាំងដោយភាគីនិមួយៗ សំរាប់ទទួលខុសត្រូវលើតំបន់ភូមិសាស្ត្រសមស្រប ការទទួលពត៌មានពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ក៏ដូចជាពត៌មានផ្សេងទៀតដែលទាក់ទងនឹងការដឹកជញ្ជូន និងការទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រាទី ៦ ។

៧- " **ក្រុមការងាររួម** " ជាអង្គភាពរបស់ភាគីនិមួយៗ ដែលបានចែងនៅក្នុងមាត្រាទី ៥ សំរាប់ទទួលខុសត្រូវលើការផ្តល់ ឬការទទួលពត៌មានដូចដែលចែងនៅក្នុងមាត្រាទី ១៣ និង១៦ ។

៨- " **ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត** " អនុលោមទៅតាមទ្រឹស្តីបរិស្ថាន ការប្រតិបត្តិនូវរាល់ដំណាក់ការអនុវត្តន៍ គឺសំដៅធានាអោយបាននូវការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថានតាមរយៈការទប់ស្កាត់រាល់ឥទ្ធិពលគ្រោះថ្នាក់ដែលកើតឡើងដោយសារសំណល់នេះ ។

៩- " **តំបន់ដែលស្ថិតនៅក្រោមច្បាប់គ្រប់គ្រងរបស់ប្រទេស** " រួមមានដី តំបន់សមុទ្រ ឬអាកាស ដែលស្ថិតនៅក្រោមការចុះបញ្ជីរព្រំដែនត្រឹមត្រូវតាមច្បាប់អន្តរជាតិ ដោយគោរពលើការការពារសុខភាពមនុស្ស និងបរិស្ថាន ។

១០- " **ប្រទេសនាំចេញ** " គឺភាគីដែលបានធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ដោយមានផែនការចាប់ផ្តើមដឹកចេញ ឬបានដឹកចេញរួចទៅហើយ ។

១១- " **ប្រទេសនាំចូល** " គឺជាភាគីដែលទទួលរងការចាក់សំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ទៅតាមផែនការកំណត់ ឬក៏ស្តុកទុកដើម្បីចាក់នៅតំបន់ក្រៅពីការកំណត់របស់ច្បាប់ ។

១២- " **ប្រទេសសំរាប់ធ្វើការដឹកជញ្ជូនឆ្លងកាត់បណ្តោះអាសន្ន** " ជាប្រទេសដែលអនុញ្ញាតអោយសកម្មភាពដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតឆ្លងកាត់ទៅកាន់ប្រទេសមួយទៀតទៅតាមការកំណត់ ។

១៣- " **ប្រទេសដែលជាប់ពាក់ព័ន្ធ** " គឺភាគីដែលជាប្រទេសនាំចេញ នាំចូល ឬឆ្លងកាត់បណ្តោះអាសន្ននូវសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតទោះបីមិនមែនជាសមាជិករបស់អនុសញ្ញានេះក៏ដោយ ។

១៤- " **បុគ្គល** " ជាបុគ្គលស្របច្បាប់ ឬជាបុគ្គលដែលមិនស្របតាមផ្លូវច្បាប់ ។

១៥- " **ម្ចាស់នាំចេញ** " ជាបុគ្គល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសនាំចេញណាមួយ ដែលបានរៀបចំការនាំចេញសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតទៅកាន់កន្លែងដទៃ ។

១៦- " **ម្ចាស់នាំចូល** " ជាបុគ្គល ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ប្រទេសនាំចូលណាមួយ ដែលបានរៀបចំការនាំចូលនូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតពីប្រទេសក្រៅ ។

១៧- " **អ្នកដឹកជញ្ជូន** " រាល់បុគ្គល ដែលអនុវត្តការដឹកជញ្ជូនផ្ទាល់នូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ពីកន្លែងមួយទៅកន្លែងមួយទៀត ។

១៨- " **ម្ចាស់បង្កើតសំណល់** " ជាបុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។ បើសិនមិនស្គាល់បុគ្គលដើម នោះអ្នកដែលកំពុងកាន់កាប់ត្រួតពិនិត្យជាម្ចាស់បង្កើតសំណល់ ។

១៩- " **ម្ចាស់បោះបង់សំណល់ចោល** " ជាបុគ្គលដែលដឹកជញ្ជូន និងបោះចោលនូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតដោយខ្លួនឯង ។

២០- " **អង្គការដែលមានគោលនយោបាយ និងសេដ្ឋកិច្ចរួម** " ជាអង្គការដែលបង្កើតឡើងដោយរដ្ឋ ឬប្រទេសឯករាជ្យជាច្រើន ។ សមាជិកនៃរដ្ឋ ឬប្រទេសឯករាជ្យដែលបានបញ្ជូនទៅធ្វើជាសមត្ថកិច្ចតាមផ្នែកនិមួយៗ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អនុសញ្ញានេះ និងបានអនុញ្ញាតត្រឹមត្រូវទៅតាមគោលការណ៍ផ្ទៃក្នុងទៅលើការចុះហត្ថលេខា ការសច្ចានុម័ត ការទទួលកិច្ចព្រមព្រៀង ភាពបញ្ជាក់ត្រឹមត្រូវ ឬក៏ការយល់ព្រម ។

២១- "**ការដឹកជញ្ជូនខុសច្បាប់** " ជាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដូចដែលបានបញ្ជាក់ក្នុងមាត្រាទី ៩ ។

## មាត្រាទី ៣
## និយមន័យលើសំណល់គ្រោះថ្នាក់របស់ប្រទេសនិមួយៗ

១- ភាគីនិមួយៗ នៅពេលចូលជាសមាជិកពេញសិទ្ធក្នុងអនុសញ្ញានេះបានរយៈពេល ៦ខែ ត្រូវរាយការណ៍ជូនលេខាធិការដ្ឋាន អំពីសំណល់ឯទៀតដែលពុំមានរាយឈ្មោះក្នុងតារាងឧបសម្ព័ន្ធទី I និងទី II ដែលត្រូវបានពិចារណា ឬកំណត់ថាជាសំណល់គ្រោះថ្នាក់ ផ្អែកទៅតាមច្បាប់របស់ប្រទេសនិមួយៗ និងតំរូវការស្តីពីកិច្ចព្រមព្រៀងផ្សេងៗទាក់ទងនឹងនិតិវិធីនៃការដឹកជញ្ជូនសំណល់ប្រភេទខាងលើនេះ ។

២- រាល់ភាគីនិមួយៗត្រូវជូនដំណឹងជាបន្តបន្ទាប់ទៅកាន់លេខាធិការដ្ឋាន អំពីការផ្លាស់ប្តូរព័ត៌មានសំខាន់ៗ ស្របតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

៣- លេខាធិការដ្ឋានត្រូវរាយការណ៍ដល់ភាគីទាំងអស់ជាបន្ទាន់ នូវព័ត៌មានដែលទទួលបានស្របទៅតាមវាក្យខ័ណ្ឌទី ១ និង ២ ក្នុងមាត្រានេះ ។

៤- អ្នកធ្វើរបាយការណ៍របស់ភាគីនិមួយៗ ដូចមានក្នុងវាក្យខ័ណ្ឌទី ៣ ត្រូវទទួលខុសត្រូវលើព័ត៌មានរបស់ខ្លួន ដែលត្រូវបានបញ្ជូនទៅអោយភាគីផ្សេងទៀតតាមរយៈលេខាធិការដ្ឋាន ។

## មាត្រាទី ៤
## កាតព្វកិច្ចទូទៅ

១-ក- ភាគីនិមួយៗមានសិទ្ធហាមឃាត់នូវការនាំយកមកចាក់ចោល នូវសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត ហើយត្រូវរាយការណ៍ដល់ភាគីដទៃទៀតនូវសេចក្តីសំរេចចិត្តរបស់ខ្លួនដោយអនុលោមតាមមាត្រាទី ១៣ ។

ខ- ភាគីនិមួយៗត្រូវហាមឃាត់ ឬមិនអនុញ្ញាតនូវការនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត

ទៅភាគីដែលបានធ្វើការហាមឃាត់រួចហើយនូវការនាំចូលសំណល់ទាំងនេះ នៅពេលបានជូនដំណឹងអនុលោមតាមវគ្គ " ក " ខាងលើ ។

គ- ភាគីនិមួយៗត្រូវហាមឃាត់ រឺមិនអនុញ្ញាតឱ្យនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត បើសិនប្រទេសនាំចូលមិនបានធ្វើបញ្ជីឯកសារស្តីពីការនាំចូលអោយបានច្បាស់លាស់ ហើយក្នុងករណីប្រទេសនាំចូលនោះ មិនបានហាមឃាត់នូវការនាំចូលសំណល់នេះ ។

២- រាល់ភាគីនិមួយៗត្រូវអនុវត្តតាមវិធានការណ៍ដូចខាងក្រោមនេះ :

ក- ត្រូវធានាថាការបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ត្រូវបានប្រើវិធីកាត់បន្ថយឱ្យនៅចំនួនអប្បបរិមា ដោយគិតគូពីហេតុប៉ះពាល់ដល់សង្គម បច្ចេកវិទ្យា និងសេដ្ឋកិច្ច ។

ខ- ធានាឱ្យមាននិតិវិធីគ្រប់គ្រាន់ដើម្បីធ្វើការចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតតាមលក្ខណៈបច្ចេកទេសបរិស្ថាន ពិសេសពង្រឹងលើផ្នែកគ្រប់គ្រងទីលានចាក់សំណល់នោះតែម្តង ។

គ- ធានាថាបុគ្គលដែលជាប់ទាក់ទងនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ រឺសំណល់ដ៏ទៃទៀតត្រូវមានការទទួលខុសត្រូវខ្ពស់ក្នុងការការពារនូវការពុលរបស់សំណល់ ដែលកើតឡើងដោយសារការគ្រប់គ្រងរបស់គេ ។ បើសិនមានករណីបំពុលត្រូវកាត់បន្ថយការបំពុល ដើម្បីការពារកុំអោយប៉ះពាល់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ។

ឃ- ធានាថាការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតនឹងត្រូវបានកាត់បន្ថយអោយនៅចំនួនអប្បបរិមាតាមទ្រឹស្តីបរិស្ថាន និងមានការគ្រប់គ្រងសំណល់អោយបានត្រឹមត្រូវដើម្បីការពារសុខភាពមនុស្ស និងគុណភាពបរិស្ថាន និងទប់ស្កាត់នូវរាល់ឥទ្ធិពលអាក្រក់ទាំងឡាយ ដែលកើតឡើងដោយសារបញ្ហាសំណល់ ។

ង- មិនអនុញ្ញាតអោយមានការនាំចេញសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ទៅកាន់ប្រទេស រឺទៅកាន់ក្រុមនៃប្រទេស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសេដ្ឋកិច្ច រឺនយោបាយរួមតែមួយ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានច្បាប់ហាមប្រាមលើការនាំចូល ឬបើសិនវាមានមូលហេតុបញ្ជាក់ថាសំណល់នឹងមិនអាចគ្រប់គ្រងបានតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយអនុលោមតាមការវិភាគដែលបានសំរេចដោយភាគីនៅក្នុងអង្គប្រជុំលើកទី១ ។

ច- ពត៌មានស្តីអំពីសំណើសុំធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក រឺសំណល់ដ៏ទៃទៀត ត្រូវផ្តល់ទៅឱ្យប្រទេសដែលជាប់ពាក់ព័ន្ធ អនុលោមតាមឧបសម្ព័ន្ធទី ៥ " ក " និងបញ្ជាក់ឱ្យច្បាស់អំពីឥទ្ធិពលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន ដែលបណ្តាលមកពីការដឹកជញ្ជូននេះ ។

ឆ- បង្ការនូវការនាំចូលសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត បើសិនជាមានហេតុផលបញ្ជាក់ថាសំណល់ទាំងនោះពុំអាចគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសបរិស្ថានបាន ។

ជ- សហការជាមួយគូភាគីផ្សេងៗ និងអង្គការនានាដោយផ្ទាល់ ឬតាមរយៈលេខាធិការដ្ឋានរួមមានការផ្សព្វផ្សាយពត៌មានលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ដើម្បីបង្កើនការគ្រប់គ្រងសំណល់ទាំងនេះតាមលក្ខណៈបច្ចេកទេសបរិស្ថាន និងសំរេចជោគជ័យក្នុងការ

ទប់ស្កាត់ការដឹកជញ្ជូនសំណល់ដោយខុសច្បាប់ ។

៣- ភាគីនិមួយៗបានកំណត់ថាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតដោយខុសច្បាប់ គឺជាបទឧក្រិដ្ឋ ។

៤- រាល់ភាគីនិមួយៗ ត្រូវអនុវត្តនូវវិធានការស្របច្បាប់ វិធានការរដ្ឋបាល និងវិធានការផ្សេងៗដើម្បីអនុវត្ត និងពង្រឹងច្បាប់ដែលមានចែងនៅក្នុងអនុសញ្ញា រួមទាំងវិធានការនានាដើម្បី ទប់ស្កាត់ និងដាក់ទណ្ឌកម្មដល់ការប្រព្រឹត្តល្មើសចំពោះអនុសញ្ញានេះ ។

៥- ភាគីនិមួយៗមិនត្រូវអនុញ្ញាតឱ្យមានការនាំចេញសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀតទៅកាន់ភាគីដែលពុំមែនជាសមាជិកអនុសញ្ញាបាសែល រឺក៏នាំចូលប្រភេទសំណល់នេះមកពីប្រទេសដែលពុំមែនជាសមាជិកអនុសញ្ញាបាសែលចូលមកកាន់ប្រទេសខ្លួនឡើយ ។

៦- ភាគីនិមួយៗមិនត្រូវយល់ព្រមនូវការសុំនាំចេញសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀតទៅចាក់ចោលក្នុងតំបន់ដែលមានរយៈទទឹង $60^{0}$អង្សា ឬទោះជាសំណល់ទាំងនោះមិនមែនជាប្រធានបទសំរាប់ការដឹកជញ្ជូនឆ្លងដែនក៏ដោយ ។

៧- លើសពីនោះទៀត ភាគីទាំងអស់ត្រូវ :

ក- ហាមឃាត់បុគ្គលទាំងអស់ ផ្អែកទៅតាមច្បាប់កំណត់របស់ប្រទេសនិមួយៗ ស្តីពីការដឹកជញ្ជូន ឬចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត លើកលែងតែបុគ្គលនោះទទួលបានការអនុញ្ញាតអោយអនុវត្តជាមុន ។

ខ- រាល់ការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត ត្រូវតែធ្វើការវេចខ្ចប់ បិទផ្លាកសញ្ញា និងដឹកជញ្ជូនដោយមានការព្រមព្រៀង និងទទួលស្គាល់តាមច្បាប់ និងតាមស្តង់ដារអន្តរជាតិ ។ រីឯរបាយការណ៍ដែលបានធ្វើឡើង ត្រូវមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

គ- រាល់ការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ត្រូវមានឯកសារភ្ជាប់ជាមួយស្តីពីចំនុចចាប់ផ្តើមដឹកជញ្ជូនចេញ និងចំនុចចាក់ចោលសំណល់ ។

៨- ភាគីនិមួយៗ ត្រូវទាមទារអោយមានការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតដែលត្រូវនាំចេញតាមលក្ខណៈបច្ចេកទេសបរិស្ថាន ក្នុងប្រទេសដែលនាំចូល ឬកន្លែងផ្សេងៗទៀត ។ គោលការណ៍ណែនាំដែលជាប្រធានបទរបស់អនុសញ្ញាអន្តរជាតិបាសែលសំរាប់ការគ្រប់គ្រងសំណល់តាមលក្ខណៈបច្ចេកទេសបរិស្ថាន នឹងត្រូវលើកយកមកធ្វើសេចក្តីសំរេចចិត្តរវាងគូភាគីទាំងសងខាងនៅក្នុងជំនួបលើកទី ១ ។

៩- ភាគីនិមួយៗត្រូវជ្រើសរើសយកវិធានការណ៍សមស្រប ដើម្បីធានាថាការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតនឹងត្រូវបានអនុញ្ញាត្ត បើសិន :

ក- ប្រទេសនាំចេញគ្មានសមត្ថភាពគ្រប់គ្រាន់ ទៅលើផ្នែកបច្ចេកទេស សំភារៈចាំបាច់សមត្ថភាព ឬទីលានចាក់អោយបានសមស្រប ដើម្បីបោះចោលសំណល់ដោយផ្អែកទៅតាមលក្ខណៈបច្ចេកទេសបរិស្ថាន និងប្រកបដោយប្រសិទ្ធិភាព ។

ខ- សំណល់ទាំងនេះ មានវត្ថុធាតុដើមសំរាប់ការកែច្នៃ និងទាញយកមកប្រើប្រាស់ឡើងវិញ ក្នុងវិស័យឧស្សាហកម្មនៃប្រទេសនាំចូល ។

គ- អនុលោមតាមការវិនិច្ឆ័យរបស់ភាគីផ្សេងទៀត ការដឹកជញ្ជូនសំណល់ឆ្លងដែននេះ នឹងត្រូវបានសំរេចដោះស្រាយដោយភាគីនិមួយៗ ក្នុងលក្ខខ័ណ្ឌនៃការវិនិច្ឆ័យដោយស្របតាមការចែងរបស់អនុសញ្ញានេះ ។

១០- កាតព្វកិច្ចរបស់ប្រទេសនិមួយៗ ដែលជាសមាជិករបស់អនុសញ្ញានេះ ត្រូវទទួលខុសត្រូវចំពោះសំណល់គ្រោះថ្នាក់ ដែលខ្លួនបានបង្កើតអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយមិនត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌផ្សេងរបស់ប្រទេសនាំចូល ឬប្រទេសដែលឆ្លងកាត់ឡើយ ។

១១- អនុសញ្ញានេះមិនបានរារាំង ដល់សេចក្តីត្រូវការបន្ថែមរបស់ភាគីនិមួយៗ ស្របតាមសេចក្តីចែងរបស់អនុសញ្ញានេះ និងអនុលោមតាមបទបញ្ញត្តិរបស់ច្បាប់អន្តរជាតិ ដើម្បីការពារសុខភាពមនុស្ស និងគុណភាពបរិស្ថានឱ្យកាន់តែប្រសើរឡើង ។

១២- អនុសញ្ញានេះមិនធ្វើអោយមានការប៉ះពាល់ ដល់អធិបតេយ្យភាពដែនសមុទ្រប្រទេសនិមួយៗ ដោយផ្អែកទៅតាមច្បាប់អន្តរជាតិ និងអំណាចច្បាប់ និងយុត្តាធិការចំពោះប្រទេស ដែលមានតំបន់សេដ្ឋកិច្ចរួម និងនៅក្នុងទ្វីបរបស់គេដោយអនុលោមតាមច្បាប់អន្តរជាតិ និងការដឹកជញ្ជូនតាមនាវាឬតាមយន្តហោះ នៃប្រទេសទាំងអស់ក៏ដូចជា តាមច្បាប់នាវាចរណ៍ និងសិទ្ធសេរីភាពដូចដែលបានចែង ក្នុងច្បាប់អន្តរជាតិ ។

១៣- ភាគីនិមួយៗត្រូវទទួលខុសត្រូវចាំបាច់ ក្នុងការពិនិត្យឡើងវិញលើលទ្ធភាពក្នុងការកាត់បន្ថយបរិមាណ ឬកំរិតជាតិពុលនៃសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ដែលបាននាំចេញទៅប្រទេសដទៃ ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។

## មាត្រា ៥
## ការបង្កើតក្រុមអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម

ដើម្បីសំរួលក្នុងការអនុវត្តន៍អនុសញ្ញានេះ ភាគីនិមួយៗត្រូវតែ :

១- ចាត់តាំង ឬបង្កើតក្រុមអាជ្ញាធរមានសមត្ថកិច្ច ឬក្រុមការងាររួមមួយ ។ ក្រុមអាជ្ញាធរមានសមត្ថកិច្ចនឹងត្រូវបានធ្វើការចាត់តាំងឡើងដើម្បីទទួលការប្រកាស ក្នុងករណីឆ្លងកាត់ប្រទេស ។

២- ពេលចូលជាសមាជិកពេញសិទ្ធរបស់អនុសញ្ញានេះបានរយៈពេលបីខែ ភាគីនិមួយៗត្រូវរាយការណ៍ជូនលេខាធិការដ្ឋានអំពីការតែងតាំងសមាសភាពនៃក្រុមអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម ។

៣- រាយការណ៍ជូនលេខាធិការដ្ឋានអោយបានរយៈពេលមួយខែ អំពីសេចក្តីសំរេចលើការផ្លាស់ប្តូរនានាដែលទាក់ទងនឹងការតែងតាំងក្រុមការងាររួម ឬក្រុមអាជ្ញាធរមានសមត្ថកិច្ចថ្មីដូចដែលបានចែងនៅក្នុងវគ្គទី ២ នៃមាត្រានេះ ។

## មាត្រា ៦
## ការដឹកជញ្ជូនឆ្លងដែនរវាងភាគីនីមួយៗ

1- ប្រទេសនាំចេញត្រូវចេញប្រកាស ឬស្នើដល់ម្ចាស់បង្កើត និងម្ចាស់នាំចេញសំណល់ឱ្យរាយការណ៍ជាលាយល័ក្ខអក្សរ តាមរយៈក្រុមអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញនោះ និងអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដែលពាក់ព័ន្ធ អំពីសំណើសុំលើការដឹកជញ្ជូនឆ្លងដែននូវសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។ ការប្រកាសនេះត្រូវមានជារបាយការណ៍ និងពត៌មានជាក់លាក់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥ "ក" រួមទាំងការប្រើប្រាស់ភាសាដែលប្រទេសនាំចូលអាចទទួលយល់ព្រម ។ សេចក្តីប្រកាសនេះ ត្រូវផ្ញើរទៅកាន់ប្រទេសដែលពាក់ព័ន្ធនឹងការដឹកជញ្ជូននេះ ។

២- ប្រទេសនាំចូលត្រូវទទួលខុសត្រូវ ក្នុងការប្រកាសជាលាយល័ក្ខអក្សរដូចជា ការអនុញ្ញាតឱ្យធ្វើការដឹកជញ្ជូនដោយមានលក្ខខ័ណ្ឌ ឬគ្មានលក្ខខ័ណ្ឌ ការបដិសេធលើការដឹកជញ្ជូន និងសំណើសុំពត៌មានបន្ថែម ។ ឯកសារថតចំលង ស្តីពីការទទួលខុសត្រូវដំណាក់កាលចុងក្រោយរបស់ប្រទេសនាំចូល ត្រូវផ្ញើរទៅកាន់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដែលជាភាគី ។

៣- ប្រទេសនាំចេញ មិនត្រូវអនុញ្ញាតអោយម្ចាស់បង្កើត ឬម្ចាស់នាំចេញសំណល់ចាប់ផ្តើមធ្វើការដឹកជញ្ជូនឆ្លងដែន លុះត្រាតែប្រទេសនាំចេញទាំងនោះទទួលបានការបញ្ជាក់ថា :

ក- អ្នកប្រកាសបានទទួលលិខិតអនុញ្ញាតពីប្រទេសនាំចូល

ខ- អ្នកប្រកាសបានទទួលការបញ្ជាក់ពីប្រទេសនាំចូលនូវកិច្ចសន្យារវាងម្ចាស់នាំចេញ និងម្ចាស់បោះបង់ចោល ដោយបញ្ជាក់ច្បាស់លាស់ពីការគ្រប់គ្រងសំណល់តាមលក្ខណៈបច្ចេកទេសបរិស្ថានត្រឹមត្រូវ ។

៤- រាល់ប្រទេសឆ្លងកាត់ដែលជាភាគី ត្រូវទទួលស្គាល់ជាបន្ទាន់ នូវបង្កាន់ដៃរបស់អ្នកប្រកាស ។ ប្រទេសដែលសំណល់ត្រូវធ្វើការឆ្លងកាត់ អាចឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល៦០ថ្ងៃសំរាប់ការអនុញ្ញាតដល់ការដឹកជញ្ជូនដោយមានលក្ខខ័ណ្ឌ ឬគ្មានលក្ខខ័ណ្ឌ និងភ្ជាប់លិខិតបដិសេធលើការអនុញ្ញាតនៃការដឹកជញ្ជូន ឬការស្នើពត៌មានបន្ថែមនានា ។

ប្រទេសនាំចេញមិនត្រូវអនុញ្ញាតអោយចាប់ដំណើការដឹកជញ្ជូន ដរាបណាមិនទាន់ទទួលលិខិតអនុញ្ញាតពីប្រទេសដែលត្រូវឆ្លងកាត់ ។ ទោះជាយ៉ាងណាក៏ដោយ បើសិននៅពេលណាមួយភាគីសំរេចថាមិនត្រូវការកិច្ចព្រមព្រៀងជាលាយលក្ខ័អក្សរក្នុងលក្ខខ័ណ្ឌទូទៅ ឬជាក់លាក់ណាមួយលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតឆ្លងកាត់ប្រទេសខ្លួន ឬមានការកែប្រែលើតំរូវការផ្សេងៗ នោះនឹងត្រូវជូនដំណឹងជាបន្ទាន់នូវសេចក្តីសំរេចរបស់ខ្លួនដល់ភាគីឯទៀត យោងតាមមាត្រាទី ១៣ ។ ក្នុងករណីយឺតយ៉ាវដោយប្រទេសនាំចេញមិនបានទទួលចំលើយតបក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីទទួលបាននូវបង្កាន់ដៃប្រកាសរបស់ប្រទេសឆ្លងកាត់ នោះប្រទេសនាំចេញអាចអនុញ្ញាតអោយម្ចាស់នាំចេញ ប្តឹងពីប្រទេសឆ្លងកាត់នោះបាន ។

៥- ក្នុងករណីដឹកជញ្ជូនសំណល់ ដែលបានកំណត់ត្រឹមត្រូវតាមច្បាប់ ឬបានចាត់ទុកជាសំណល់គ្រោះថ្នាក់ លុះត្រាកំណត់ដោយ :

ក- ប្រទេសនាំចេញ ត្រូវអនុវត្តទៅតាមតំរូវការក្នុងវគ្គទី ៩ នៃមាត្រានេះ ដែលលើកពីករណីពាក់ព័ន្ធនឹងម្ចាស់នាំចូល ម្ចាស់បោះបង់ចោល ហើយប្រទេសនាំចូលត្រូវស្នើសុំ Mutatis Mutendis ចំពោះម្ចាស់នាំចេញ និងប្រទេសនាំចេញរៀងៗខ្លួន ។

ខ- ប្រទេសនាំចូល ឬដោយប្រទេសឆ្លងកាត់ដែលជាគូភាគីជាមួយប្រទេសនាំចូល ត្រូវអនុវត្តទៅតាមតំរូវការក្នុងវគ្គទី ១ ៣ ៤ និង ៦ នៃមាត្រានេះ ហើយប្រទេសនាំចេញត្រូវស្នើសុំ Mutatis Mutendis ចំពោះម្ចាស់នាំចូល ម្ចាស់បោះបង់ចោល ឬប្រទេសនាំចូលរៀងៗខ្លួន ។

គ- សេចក្តីចែងក្នុងវគ្គទី៤ ចំពោះប្រទេសដែលត្រូវឆ្លងកាត់ត្រូវអនុវត្តសំរាប់ប្រទេសទាំងអស់នេះ ។

៦- ប្រទេសនាំចេញជាកម្មវត្ថុនៃការផ្តល់លិខិតអនុញ្ញាតដោយប្រទេសជាប់ពាក់ព័ន្ធ សំរាប់ការអនុញ្ញាតម្ចាស់បង្កើត ឬម្ចាស់នាំចេញប្រើប្រាស់ប្រកាសទូទៅ អំពីការដឹកជញ្ជូនជាប្រចាំសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដែលមានលក្ខណៈរូប និងលក្ខណៈគីមីដូចគ្នាទៅប្រទេសដែលទទួលសំណល់ដោយត្រូវឆ្លងកាត់តាមទីចាត់ការគយផ្នែកច្រកចេញនៃប្រទេសនាំចេញ និងតាមរយៈទីចាត់ការគយផ្នែកច្រកចូលនៃប្រទេសនាំចូល ។ ក្នុងការឆ្លងកាត់ ត្រូវទាក់ទងនឹងទីចាត់ការគយផ្នែកច្រកចេញ និងច្រកចូលរបស់ប្រទេសដែលត្រូវឆ្លងកាត់ ។

៧- តាមរយៈលិខិតអនុញ្ញាតជាផ្លូវការ ប្រទេសពាក់ព័ន្ធអាចប្រើប្រាស់ប្រកាសទូទៅ ដោយយោងតាមសេចក្តីចែងក្នុងវគ្គទី ៦ លើការផ្តល់ពត៌មានជាក់លាក់ដូចជាអំពីបរិមាណពិតប្រាកដ ឬបញ្ជីរៀបរាប់ពីរយៈពេលដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ។

៨- លិខិតអនុញ្ញាត និងការប្រកាសទូទៅទាក់ទងនឹងវគ្គទី ៦ និង ៧ អាចមានអនុភាពប្រើប្រាស់លើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀតក្នុងរយៈពេលអតិបរិមាចំនួន ១២ខែ ។

៩- ភាគីទាំងឡាយ ត្រូវស្នើដល់បុគ្គល ដែលទទួលខុសត្រូវលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត ឱ្យចុះហត្ថលេខាក្នុងឯកសារ ឬក្នុងបង្កាន់ដៃ ។ ហើយក៏ត្រូវស្នើផងដែរដល់ប្រទេសទទួលសំណល់ឱ្យរាយការណ៍ជូនម្ចាស់នាំចេញ និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញនូវបង្កាន់ដៃ ដែលបញ្ជាក់ថាបានបំពេញការចាក់ចោលសំណល់ទៅតាមសេចក្តីប្រកាស ។ បើសិនប្រទេសនាំចេញមិនបានទទួលពត៌មាននេះ នោះអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ឬម្ចាស់នាំចេញត្រូវធ្វើការជូនដំណឹងទៅកាន់ប្រទេសនាំចូល ។

១០- ការប្រកាស និងការឆ្លើយតបដែលជាតំរូវការរបស់មាត្រានេះ ត្រូវផ្ញើបញ្ជូនទៅអាជ្ញាធររបស់ភាគីពាក់ព័ន្ធ ឬអាជ្ញាធររដ្ឋាភិបាលក្នុងករណី ដែលពុំមែនជាគូភាគីក្នុងការដឹកជញ្ជូន ។

១១- រាល់ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតត្រូវតែមានការធានារ៉ាប់រងវិញ្ញាបនប័ត្រ ឬការធានាខុសត្រូវដែលជាសំណូមពររបស់ប្រទេសនាំចូល និងប្រទេសឆ្លងកាត់ ដែលជាគូភាគី ។

## មាត្រាទី ៧
## ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ពីប្រទេសមួយជាសមាជិករបស់អនុសញ្ញាអន្តរជាតិបាសែល ទៅកាន់ប្រទេសមួយទៀត ដែលមិនមែនជាសមាជិក

វគ្គទី ១ នៃមាត្រាទី ៦ របស់អនុសញ្ញានេះត្រូវអោយមានការស្នើសុំ Mutatis Mutandis ដើម្បីធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតពីប្រទេសមួយជាសមាជិកអនុសញ្ញាអន្តរជាតិបាសែលទៅកាន់ប្រទេសមួយទៀត ដែលមិនមែនជាគូភាគី ។

## មាត្រាទី ៨
## ការទារសំរាប់ការនាំចូលជាថ្មីវិញ

នៅពេលដែលការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ត្រូវបានអនុញ្ញាតដោយប្រទេសពាក់ព័ន្ធ ប៉ុន្តែប្រធានបទមួយចំនួនដែលបានចែងក្នុងអនុសញ្ញាមិនទាន់បានបំពេញអោយបានគ្រប់ជ្រុងជ្រោយដូចមានក្នុងកិច្ចព្រមព្រៀង នោះការចាក់សំណល់នឹងចាត់ទុកថាពុំស្របតាមលក្ខណៈបច្ចេកទេសបរិស្ថាន នោះប្រទេសនាំចេញត្រូវធានានឹងយកសំណល់នោះត្រឡប់ទៅវិញក្នុងកំឡុងពេល ៩០ថ្ងៃ គិតចាប់ពីថ្ងៃ ដែលប្រទេសនាំចូលបានជូនដំណឹងទៅប្រទេសនាំចេញ និងទៅលេខាធិការដ្ឋានអនុសញ្ញាអន្តរជាតិ "បាសែល" ឬគិតចាប់ពីពេលដែលប្រទេសជាប់ពាក់ព័ន្ធ បានព្រមព្រៀងគ្នា ។ នៅទីបញ្ចប់ប្រទេស នាំចេញនិងប្រទេសត្រូវឆ្លងកាត់មិនត្រូវបង្កការរារាំង រំខានការដឹកជញ្ជូនសំណល់ទាំងនេះទៅប្រទេសនាំចេញទេ ។

## មាត្រាទី ៩
## ការដឹកជញ្ជូនខុសច្បាប់

១- គោលបំណងរបស់អនុសញ្ញានេះ សំដៅលើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ដែលចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់បើ :
- ក- មិនបានផ្តល់ការប្រកាសដល់ប្រទេសជាប់ពាក់ព័ន្ធទាំងអស់ ដូចមានចែងក្នុងអនុសញ្ញានេះ ។
- ខ- គ្មានការយល់ព្រមពីប្រទេសដែលជាប់ពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានេះ ។
- គ- លិខិតអនុញ្ញាតរបស់ប្រទេសជាប់ពាក់ព័ន្ធត្រូវបានការកែបន្លំ ឬមិនត្រឹមត្រូវតាមច្បាប់ ។
- ឃ- មិនបានបញ្ជាក់គ្រប់គ្រាន់តាមឯកសារ
- ង- លទ្ធផលនៃការបោះបង់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ផ្ទុយពីគោលការណ៍របស់អនុសញ្ញា និងច្បាប់អន្តរជាតិ ។

២- ក្នុងករណីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់ ប្រទេសនាំចេញត្រូវធានាខុសត្រូវចំពោះសំណល់របស់គេ :
- ក- ម្ចាស់នាំចេញ ឬម្ចាស់បង្កើតសំណល់ ត្រូវដឹកជញ្ជូនត្រលប់ទៅប្រទេសខ្លួន ឬទៅប្រទេសនាំចេញវិញ បើសិនចាំបាច់ គឺត្រូវដឹកជញ្ជូនដោយខ្លួនឯង ។

ខ- អនុលោមតាមសេចក្តីចែងរបស់អនុសញ្ញា ក្នុងកំឡុងពេល៣០ថ្ងៃក្រោយពីមានការជូនដំណឹងចំពោះការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតមានលក្ខណៈខុសច្បាប់ ប្រទេសនាំចេញត្រូវដឹកជញ្ជូនសំណល់របស់ខ្លួន ទៅកាន់ប្រទេសនាំចេញវិញ ។ រីឯភាគីពាក់ព័ន្ធ មិនត្រូវប្រឆាំងរាំងផល់ការដឹកជញ្ជូនសំណល់នេះទេ ។

៣- ក្នុងករណីដែលការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ចាត់ទុកជាការដឹកជញ្ជូនខុសច្បាប់ដែលបណ្តាលពីការដឹកនាំរបស់ម្ចាស់នាំចូល ឬម្ចាស់បោះបង់ចោល នោះប្រទេសនាំចូលត្រូវធានាថាសំណល់នេះ ត្រូវបានចាក់ចោលតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយម្ចាស់នាំចូល ឬដោយបុគ្គលដែលទទួលខុសត្រូវក្នុងការចាក់សំណល់នេះ បើសិនចាំបាច់ដោយខ្លួនឯងក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃនៃការដឹកជញ្ជូនខុសច្បាប់បានដឹងឮដោយប្រទេសនាំចូល ឬក្នុងរយៈពេលដែលប្រទេសពាក់ព័ន្ធមានការយល់ព្រមគ្នា ។ នៅទីបញ្ចប់ប្រទេសពាក់ព័ន្ធ ត្រូវសហការគ្នាក្នុងការចាក់សំណល់ចោល តាមលក្ខណៈបច្ចេកទេសបរិស្ថាន ។

៤- ក្នុងករណីការទទួលខុសត្រូវលើការដឹកជញ្ជូនខុសច្បាប់ មិនអាចកំណត់បានទៅលើម្ចាស់នាំចេញ ម្ចាស់បង្កើត ម្ចាស់នាំចូល ឬអ្នកចាក់សំណល់ចោល នោះគូភាគីពាក់ព័ន្ធ ឬភាគីផ្សេងៗទៀត ត្រូវធានាថាតាមរយៈការសហការគ្នា ការបោះបង់សំណល់ដែលមានបញ្ហាត្រូវប្រព្រឹត្តឡើងយ៉ាងឆាប់រហ័សតាមលក្ខណៈបច្ចេកទេសបរិស្ថាននៃប្រទេសនាំចេញ និងប្រទេសនាំចូល ឬកន្លែងផ្សេងៗទៀតដែលគិតថាជាកន្លែងសមរម្យ ។

៥- ភាគីនិមួយៗ ត្រូវធ្វើការបង្ហាញពីច្បាប់ជាតិ ឬច្បាប់ក្នុងស្រុកដ៏សមស្របសំរាប់ការពារ និងដាក់ទណ្ឌកម្មផល់ការដឹកជញ្ជូនសំណល់ខុសច្បាប់ ។ ភាគីនិមួយៗត្រូវសហការគ្នាអនុវត្តទិសដៅមាត្រានេះអោយមានប្រសិទ្ធភាព ។

## មាត្រាទី ១០

## ការសហការជាលក្ខណៈអន្តរជាតិ

១- ភាគីនិមួយៗ ត្រូវសហការគ្នាដើម្បីបង្កើន និងសំរេចអោយបានលទ្ធផលល្អក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតតាមលក្ខណៈបច្ចេកទេសបរិស្ថាន ។

២- នៅទីបញ្ចប់នេះភាគីនិមួយៗត្រូវ :

ក- ផ្អែកទៅតាមសំណើ ត្រូវបង្កើតពត៌មានដែលមានលក្ខណៈទ្វេភាគី ឬពហុភាគីដើម្បីបង្កើនការត្រួតពិនិត្យឡើងវិញ លើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត រាប់បញ្ចូលទាំងស្តង់ដារតាមបច្ចេកទេស និងការអនុវត្តន៍ទៅលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ខ- សហការគ្នាក្នុងការត្រួតពិនិត្យឡើងវិញ នូវឥទ្ធិពលប៉ះពាល់ទៅលើសុខភាពមនុស្ស និងបរិស្ថានដែលបណ្តាលមកពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

គ- សហការគ្នាក្នុងការអនុវត្តន៍តាមច្បាប់ជាតិ បទបញ្ជា និងគោលនយោបាយរបស់ភាគីនិមួយៗ ក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍បច្ចេកវិទ្យាបរិស្ថានថ្មី ដែលបង្កើតបរិមាណសំណល់ក្នុង

កំរិតទាប និងបង្កើនការកែប្រែបច្ចេកវិទ្យាដែលមានស្រាប់ ដើម្បីកាត់បន្ថយការបង្កើតសំណល់ និងសំរេចនូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅតាមលក្ខណៈបច្ចេកទេសបរិស្ថាន រាប់បញ្ចូលទាំង ការសិក្សាលើឥទ្ធិពលសេដ្ឋកិច្ច សង្គម និងស្ថានភាពបរិស្ថាន ដែលបណ្តាល មកពីបច្ចេកវិទ្យាថ្មី ឬបច្ចេកវិទ្យាដែលបានកែលំអរ ។

ឃ- សហការគ្នាយ៉ាងសកម្ម ក្នុងការអនុវត្តន៍ច្បាប់ជាតិ បទបញ្ញា និងគោលនយោបាយរបស់ ភាគីនិមួយៗ ក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យា និងប្រព័ន្ធគ្រប់គ្រងដែលទាក់ទងនឹងការគ្រប់គ្រង សំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ផ្អែកតាមលក្ខណៈបច្ចេកទេសបរិស្ថាន ។ ត្រូវ សហការផងដែរក្នុងការពង្រីក និងពង្រឹងសមត្ថភាពជំនាញជាមួយភាគីឯទៀត ជាពិសេស វាជាតំរូវការ និងជាសំណើផ្នែកជំនួយបច្ចេកទេសចំពោះបញ្ហាគ្រប់គ្រងសំណល់នេះ ។

ង- សហការគ្នា ក្នុងការពង្រឹងគោលការណ៍ណែនាំបច្ចេកទេស និងច្បាប់អនុវត្តការងារ ។

៣- ភាគីនិមួយៗ ត្រូវអនុវត្តការងារអោយបានល្អប្រសើរ ក្នុងន័យរួមសហការគ្នាដើម្បីជួយប្រទេស ដែលកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តន៍មាត្រាទី ៤ ចំនុច ក ខ គ និង ឃ ក្នុងវគ្គទី ២ នេះ ។

៤- គិតគូដល់សេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ការសហការគ្នារវាងភាគីនិមួយៗ និង សមត្ថកិច្ចរបស់អង្គការអន្តរជាតិ ដោយលើកទឹកចិត្តដើម្បីបង្កើន Inter-alia ចំណេះដឹងរបស់ ប្រជាជនអោយកាន់តែប្រសើរឡើងលើការពង្រឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀត និងការជ្រើសរើសយកបច្ចេកវិទ្យាថ្មីដែលមានបរិមាណសំណល់ក្នុងកំរិតទាប ។

## មាត្រាទី ១១
## កិច្ចព្រមព្រៀងមានលក្ខណៈជាទ្វេភាគី ពហុភាគី និងតំបន់

១- ទោះបីមានការចែងក្នុងមាត្រាទី ៤ វគ្គទី ៥ក៏ដោយ ភាគីនិមួយៗអាចចូលរួមបង្កើតកិច្ចព្រមព្រៀង ជាលក្ខណៈទ្វេភាគី ពហុភាគី ឬ តំបន់រួមដោយផ្អែកទៅលើការដឹកជញ្ជូនឆ្លងដែននូវសំណល់ គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតជាមួយគូភាគីជាសមាជិក ឬមិនមែនជាសមាជិករបស់អនុសញ្ញា នេះបាន ដោយស្ថិតក្នុងលក្ខខ័ណ្ឌព្រមព្រៀងគ្នា ឬរៀបចំដឹកជញ្ជូនសំណល់ ដោយមិនអនុវត្ត ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតខុសពីការគ្រប់គ្រងតាមបច្ចេកទេសបរិស្ថាន ដូចមានចែងក្នុងអនុសញ្ញានេះ ។ ការឯកភាពគ្នា ឬការរៀបចំការដឹកជញ្ជូនសំណល់នេះ ត្រូវបញ្ជាក់ច្បាស់លើសេចក្តីចែង ស្តីអំពីការគ្រប់គ្រងបរិស្ថានដែលជាគោលបំណងរបស់អនុសញ្ញា អន្តរជាតិបាសែល ហើយជាពិសេសគិតគូលើផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

២- ភាគីនិមួយៗត្រូវរាយការណ៍ដល់លេខាធិការដ្ឋានអំពីកិច្ចព្រមព្រៀងលក្ខណៈជាទ្វេភាគី ពហុភាគី តំបន់ ឬការរៀបចំណាមួយយោងទៅតាមវគ្គទី ១ ដែលគេបានចូលរួមក្នុងកិច្ចព្រមព្រៀងរបស់ អនុសញ្ញា ក្នុងទិសដៅត្រួតពិនិត្យការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតឆ្លងដែន ដែលធ្វើឡើងដោយគូភាគីដែលស្ថិតក្នុងកិច្ចព្រមព្រៀងនេះ ។ សេចក្តីចែងនៃអនុសញ្ញានេះ

មិនធ្វើអោយមានការប្រែប្រួលលើការដឹកជញ្ជូនឆ្លងដែន ដែលប្រព្រឹត្តឡើងស្របតាមកិច្ចព្រមព្រៀង ដោយអនុវត្តការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត តាមលក្ខណៈបច្ចេកទេសបរិស្ថានត្រឹមត្រូវទៅតាមតម្រូវការរបស់អនុសញ្ញា ។

## មាត្រាទី ១២
## ការពិគ្រោះលើការទទួលខុសត្រូវរបស់អនុសញ្ញាអន្តរជាតិបាសែល

រាល់ភាគីនីមួយៗត្រូវសហការត្រួតពិនិត្យដើម្បីអនុមតិលើគោលការណ៍រៀបចំច្បាប់ និងនីតិវិធីលើការទទួលខុសត្រូវ និងការចេញសងរាល់ការខូចខាតទាំងឡាយ ដែលបណ្តាលមកពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតឆ្លងដែន ។

## មាត្រាទី ១៣
## ការបញ្ជូនពត៌មាន

១- ភាគីនីមួយៗត្រូវមានការយល់ដឹង និងធានាភ្ជាប់វាក្នុងករណីមានគ្រោះថ្នាក់ចៃដន្យ នៅពេលគេកំពុងធ្វើការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ឬពេលចាក់ចោល ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថានក្នុងប្រទេសផ្សេងៗទៀត ភាគីនោះត្រូវប្រកាសជូនដំណឹងជាបន្ទាន់ ។

២- គូភាគីនីមួយៗត្រូវរាយការណ៍ដល់គ្រប់ភាគីនានា តាមរយៈលេខាធិការដ្ឋានអំពី :

ក- ការផ្លាស់ប្តូរត្រូវប្រព្រឹត្តតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួមអនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៥ ។

ខ- ការផ្លាស់ប្តូរនិយមន័យរបស់សំណល់គ្រោះថ្នាក់តាមប្រទេសនីមួយៗរបស់ខ្លួន អនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៣ អោយបានឆាប់រហ័សទៅតាមលទ្ធភាព ។

គ- សេចក្តីសំរេចនានា ដែលធ្វើឡើងដោយភាគីនីមួយៗ មិនអាចចាត់ទុកជាសេចក្តីយល់ព្រមរួម ឬផ្នែកខ្លះក្នុងការនាំចូលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតទៅចាក់ចោលនៅតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ជាតិនៃភាគីនោះ ។

ឃ- សេចក្តីសំរេចនានា ដែលកំណត់ឡើងដោយភាគីនីមួយៗ សំដៅករិតកំណត់ ឬហាមឃាត់ការនាំចេញសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ង- តម្រូវការពត៌មានផ្សេងៗ អនុលោមតាមសេចក្តីចែងក្នុងវគ្គទី ៤ នៃមាត្រានេះ ។

៣- ភាគីនីមួយៗ ដែលមានច្បាប់ និងបទបញ្ញត្តិនានា ត្រូវធ្វើរបាយការណ៍ដល់អង្គសន្និសិទ្ធភាគីតាមរយៈលេខាធិការដ្ឋាន ស្របតាមសេចក្តីចែងក្នុងមាត្រាទី ១៥ មុនពេលបំណាច់ឆ្នាំ ។ នៅក្នុងរបាយការណ៍នៃឆ្នាំកន្លងទៅ ត្រូវសរសេររាយការណ៍អំពី :

ក- ការជ្រើសតាំងសមាសភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ឬក្រុមការងាររួម អនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ៥ ។

ខ- ពត៌មានស្តីពីការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀតដែលគេបានពាក់ព័ន្ធរួមមាន :

- បរិមាណនៃការនាំចេញ ប្រភេទ លក្ខណៈ ប្រទេសដែលជាគោលដៅចាក់ចោល ប្រទេសឆ្លងកាត់ និងនីតិវិធីចាក់សំណល់ ដូចមានចែងនៅក្នុងសេចក្តីប្រកាស ។
- បរិមាណនៃការនាំចូល ប្រភេទ លក្ខណៈ ប្រភពបង្កើត និងនីតិវិធីនៃការចាក់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។
- ការបោះបង់ចោលដែលមិនលើសពីគំរោង ។
- ការខំប្រឹងប្រែងកាត់បន្ថយបរិមាណសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ជាពិសេសសំដៅលើការដឹកជញ្ជូន ។

គ- ពត៌មានស្តីពីវិធានការ ដែលត្រូវបានអនុម័តដើម្បីអនុវត្តនៅក្នុងអនុសញ្ញានេះ ។

ឃ- ពត៌មានស្ថិតិពិតប្រាកដ ត្រូវបានចងក្រងឡើងពីឥទ្ធិពលនៃការប៉ះពាល់ដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ដែលជាមូលហេតុបណ្តាលមកពី ការបង្កើត ការដឹកជញ្ជូន និងការបោះបង់ចោលនៃសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ។

ង- ពត៌មានទាក់ទងនឹងកិច្ចព្រមព្រៀងជាលក្ខណៈទ្វេភាគី ពហុភាគី តំបន់រួម និងការរៀបចំកិច្ចព្រមព្រៀងដោយអនុលោមតាមសេចក្តីចែងក្នុងមាត្រាទី ១១ នៃអនុសញ្ញានេះ ។

ច- ពត៌មានស្តីពីភាពគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងពេលដឹកជញ្ជូន និងពេលចាក់ចោលសំណល់គ្រោះថ្នាក់ រឺសំណល់ដទៃទៀត និងពត៌មានស្តីអំពីវិធានការណ៍ដោះស្រាយបញ្ហានេះ។

ឆ- ពត៌មានលើការជ្រើសរើសវិធីសាស្ត្រចាក់សំណល់នៅក្នុងតំបន់ ដែលគ្រប់គ្រងដោយច្បាប់ជាតិ។

ជ- ពត៌មានស្តីអំពីវិធានការណ៍ទទួលខុសត្រូវលើការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីដើម្បីកាត់បន្ថយ រឺបំបាត់ការផលិតសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ឈ- ពត៌មានស្តីអំពីបញ្ហាផ្សេងៗ ដែលអង្គសន្និសិទភាគីចាត់ទុកថាមានការពាក់ព័ន្ធ ។

៤- ភាគីនីមួយៗដែលមានច្បាប់ជាតិនិងបទបញ្ញត្តិ ត្រូវធានាថារាល់សេចក្តីប្រកាសចំលងស្តីពីការអនុញ្ញាតលើ ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឬសំណល់ដទៃទៀត និងភាពទទួលខុសត្រូវ ចំពោះការដឹកជញ្ជូននេះនឹងត្រូវផ្ញើរដល់លេខាធិការដ្ឋាន នៅពេលភាគីយល់ឃើញថាការដឹកជញ្ជូនសំណល់ ទាំងនេះអាចបង្កការប៉ះពាល់ដល់បរិស្ថាន ។

## មាត្រាទី ១៤
## ផ្នែកថវិកា

១- ភាគីនីមួយៗបានឯកភាពថា អនុលោមតាមតំរូវការជាក់ស្តែងក្នុងតំបន់ និងអនុតំបន់ផ្សេងៗគ្នាដូចនេះត្រូវតែបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាល និងផ្លាស់ប្តូរបច្ចេកវិទ្យានៅក្នុងតំបន់ និងអនុតំបន់ដែលទាក់ទងនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត និងការកាត់បន្ថយការបង្កើតសំណល់ ។ ភាគីនីមួយៗត្រូវដោះស្រាយបង្កើតយន្តការថវិកាដោយខ្លួនឯង ។

២- ភាគីនិមួយៗត្រូវគិតគូទៅលើការបង្កើតថវិកា ដើម្បីជួយជាមូលដ្ឋានបណ្តោះអាសន្នក្នុងករណីបន្ទាន់ ដើម្បីកាត់បន្ថយការខូចខាតពីគ្រោះថ្នាក់ ដែលកើតឡើងដោយសារការដឹកជញ្ជូនឆ្លងដែន នៃសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ឬក្នុងកំឡុងពេលនៃដំណើរការចាក់ចោលសំណល់ទាំងនោះ ។

## មាត្រាទី ១៥
## អង្គសន្និសិទរបស់ភាគី

១- អង្គសន្និសិទ្ទរបស់ភាគី គឺជាការបង្កើតឡើងតាមរយៈភាគីទាំងអស់ ។ អង្គប្រជុំទីមួយនៃអង្គសន្និសិទរបស់ភាគី ត្រូវបានកោះអញ្ជើញដោយប្រធាននាយកប្រតិបត្តិកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP ) មុនរយៈពេលមួយឆ្នាំបន្ទាប់ពីចូលជាសមាជិកពេញសិទ្ធរបស់អនុសញ្ញានេះ ។ បន្ទាប់មកអង្គប្រជុំវិសាមញ្ញនៃអង្គសន្និសិទភាគី នឹងត្រូវប្រារព្ធឡើងក្នុងរយៈពេលទៀងទាត់មួយ ដែលកំណត់ដោយអង្គសន្និសិទ នាសម័យប្រជុំលើកទីមួយ ។

២- អង្គប្រជុំវិសាមញ្ញបន្ថែមរបស់អង្គសន្និសិទភាគី ត្រូវប្រារព្ធធ្វើក្នុងពេលផ្សេងទៀត បើសិនជាអង្គសន្និសិទចាត់ទុកជាការចាំបាច់ ឬតាមសំណើសុំរបស់ភាគីណាមួយ ដោយមានសំលេងគាំទ្រមួយភាគបីពីភាគីទាំងអស់ ។ ក្រោយពេលទទួលបានសំណើសុំក្នុងរយៈពេល ៦ខែ លេខាធិការដ្ឋានត្រូវផ្តល់ដំណឹងអំពីសំណើនោះជូនភាគីទាំងអស់ ។

៣- ក្នុងអង្គសន្និសិទ ភាគីនិមួយៗត្រូវធ្វើការឯកភាព និងទទួលយល់ព្រម ដោយអនុម័តច្បាប់ស្តីពីបែបបទសំរាប់សន្និសិទរបស់ភាគី និងសំរាប់បញ្ហាផ្សេងៗ ក៏ដូចជាច្បាប់ថវិកា សំរាប់កំនត់ការចូលរួមបរិច្ចាកថវិកាផ្ទាល់របស់ភាគីនិមួយៗចំពោះអនុសញ្ញានេះ ។

៤- នៅក្នុងអង្គប្រជុំលើកទីមួយ ភាគីនិមួយៗ ត្រូវស្វែងយល់ពីវិធានការចាំបាច់បន្ថែមដើម្បីជួយបំប៉នចំណេះដឹងបន្ថែមលើការងារទទួលខុសត្រូវក្នុងការការពារ និងការថែរក្សាបរិស្ថានផ្នែកទឹកសមុទ្រដែលមានក្នុងបរិបទនៃអនុសញ្ញានេះ ។

៥- សន្និសិទភាគី ត្រូវរក្សាបន្តរការត្រួតពិនិត្យឡើងវិញជាប្រចាំ និងធ្វើការវាយតំលៃលទ្ធផលនៃការអនុវត្តន៍របស់សន្និសិទ្ធ និងលើសពីនេះត្រូវ :

ក- ជួយជំរុញអោយកាន់តែមានភាពចុះសំរុងគ្នាលើការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការនានាសំរាប់កាត់បន្ថយភាពគ្រោះថ្នាក់នៃសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដល់សុខភាពមនុស្ស និងគុណភាពបរិស្ថាន ។

ខ- ធ្វើការពិគ្រោះនិងទទួលយល់ព្រម ទៅតាមតំរូវការ ឬធ្វើវិសោធនកម្មលើសន្និសិទ្ធ និងឧបសម្ព័ន្ធរបស់វា ដោយពិភាក្សាលើពត៌មានសំខាន់ៗ ដូចជាអ៊ីនធ័រអាលីយ៉ា (Inter- alia) ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន ។

គ- ធ្វើការពិគ្រោះ និងទទួលខុសត្រូវលើការងារបន្ថែម ដែលអាចជាតំរូវការក្នុងការអនុវត្តន៍ឱ្យបានសំរេចនូវគោលបំណងរបស់អនុសញ្ញានេះ ក្នុងការបង្ហាញនូវបទពិសោធន៍ដែលធ្លាប់សំរេច

បានជោគជ័យក្នុងការងាររបស់ខ្លួន និងបទពិសោធន៍ក្នុងការងាររៀបចំភាគីអោយមានភាពចុះសំរុងគ្នាលើសេចក្តីចែងក្នុងមាត្រាទី ១១ ។

ឃ- ធ្វើការពិគ្រោះ និងទទួលយល់ព្រមលើពិធីការផ្សេងៗ នៅពេលមានសំណើ ។

ង- ចាត់តាំងបង្កើតអោយមានបុគ្គលសំរាប់ជំនួយការងាររបស់អនុសញ្ញា បើសិនចាត់ទុកថាជាការចាំបាច់ ។

៦- អង្គការសហប្រជាជាតិ អង្គភាពពិសេសរបស់ UN ក៏ដូចជាប្រទេស ដែលមិនមែនជាភាគីរបស់អនុសញ្ញានេះទេ អាចចូលរួមជាអ្នកសង្កេតការណ៍ក្នុងអង្គប្រជុំមួយនៃអង្គសន្និសិទ្ធរបស់ភាគី ។ បុគ្គលណា ឬភ្នាក់ងារដទៃទៀត ទោះបីជាបំពីការងារអោយជាតិ អន្តរជាតិ អន្តររដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាលណាមួយ ដែលមានជំនាញច្បាស់លាស់ទាក់ទងនឹងសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ហើយបានជូនដំណឹងដល់លេខាធិការដ្ឋាន អំពីគោលបំណងចង់ចូលរួមក្នុងអង្គប្រជុំរបស់អង្គសន្និសិទ្ធភាគីក្នុងនាមជាអ្នកសង្កេតការណ៍នឹងអាចយល់ព្រម លើកលែងតែមានសំលេងមួយភាគបីរបស់អង្គសន្និសិទ្ធភាគីបានជំទាស់ ។

៧- អង្គសន្និសិទ្ធរបស់ភាគី ត្រូវទទួលរ៉ាប់រងរយៈពេលបីឆ្នាំ បន្ទាប់ពីចូលជាធរមានក្នុងអនុសញ្ញានេះ និងរាល់ ៦ឆ្នាំម្តង ត្រូវធ្វើការវាយតំលៃលើលទ្ធផលនិមួយៗ ហើយបើមានការចាំបាច់នឹងពិភាក្សាលើការអនុម័តទាំងស្រុងឬលើផ្នែកខ្លះនៃច្បាប់ហាមឃាត់ ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ដើម្បីជាការជួយបង្ហាញអំពីពត៌មានថ្មីបំផុតនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសេដ្ឋកិច្ច ។

## មាត្រាទី ១៦
## លេខាធិការដ្ឋាន

១- តួនាទីរបស់លេខាធិការដ្ឋាន :

ក- រៀបចំ និងចាត់ចែងការប្រជុំ តាមសេចក្តីចែងក្នុងមាត្រាទី ១៥ និង ១៧ ។

ខ- រៀបចំ និងបញ្ជូនរបាយការណ៍ ផ្អែកទៅលើពត៌មានដែលបានទទួល ស្របតាមមាត្រាទី ៣ ៤ ៦ ១១ និងទី ១៣ ហើយក៏ដូចជាពត៌មាននានា ដែលទទួលបាននៅក្នុងអង្គប្រជុំលើការផ្លាស់ប្តូរសមាសភាពក្នុងមាត្រាទី ១៥ ឬពត៌មានដែលបានទទួលពីអង្គភាពក្នុង និងក្រៅរដ្ឋាភិបាល ។

គ- រៀបចំរបាយកាណ៍ពីសកម្មភាពលើការអនុវត្តន៍តួនាទីរបស់ខ្លួន ស្របតាមអនុសញ្ញានេះហើយរាយការណ៍ជូនទៅអង្គសន្និសិទ្ធភាគី ។

ឃ- ធានាលើការសំរបសំរួលផ្នែកទំនាក់ទំនងការបរទេស ជាពិសេសលើផ្នែកចាត់តាំង និងការរៀបចំកិច្ចសន្យាផ្សេងៗ ដែលទាមទារឱ្យមានប្រសិទ្ធិភាពខ្ពស់ ក្នុងការបោះបង់ចោលសំណល់គ្រោះថ្នាក់ និងសំណល់ដទៃទៀត ។

ង- ធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងាររួម ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី ៥ របស់អនុសញ្ញានេះ ។

ច- ប្រមូលពត៌មាននានាស្តីពីការដ្ឋានជាតិ ឬមធ្យោបាយនានាទាក់ទងនឹងការបោះបង់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដ៏ទៃទៀតរបស់ភាគីនិមួយៗ ហើយធ្វើការផ្សព្វផ្សាយពត៌មានទាំងនេះដល់ភាគីឯទៀត ។

ឆ- ទទួល និងបញ្ជូនបន្តរាល់ពត៌មាននានាពីភាគីមួយទៅភាគីមួយទៀតអំពី :

- ប្រភពជំនួយផ្នែកបច្ចេកទេស និងផ្នែកបណ្តុះបណ្តាល
- ជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រ
- គន្លឹះនៃការណែនាំ និងឯកទេស
- ការរកប្រភពធនធាន
- **នៅពេលមានសំណើ លេខាធិការដ្ឋានបានជួយភាគីនិមួយៗតាមការជាក់ស្តែង ដូចជាផ្នែក:**
- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់អនុសញ្ញានេះ
- ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត
- បច្ចេកវិទ្យាបរិស្ថានដែលទាក់ទងនឹងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតដូចជាបច្ចេកវិទ្យាកាត់បន្ថយសំណល់ និងធ្វើអោយគ្មានសំណល់ ។
- ការវាយតំលៃលើសមត្ថភាព និងការជ្រើសរើសទីលាននៃការបោះបង់ចោលសំណល់ ។
- ការត្រួតពិនិត្យសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ។
- និងការទទួលខុសត្រូវ នៅពេលមានគ្រោះអាសន្នដោយសារសំណល់ ។

ជ- ផ្តល់ពត៌មានតាមសំណើរបស់ភាគីនីមួយៗលើទីប្រឹក្សា ឬការផ្តល់យោបល់អំពីវិធីសាស្ត្រនានាដែលធ្លាប់សំរេចបានលទ្ធផលល្អកន្លងមក សំរាប់ជាជំនួយលើការពិនិត្យពិច័យចំពោះការប្រកាសពីសកម្មភាពដឹកជញ្ជូនឆ្លងដែន ការព្រមព្រៀងលើការវេចខ្ចប់សំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀត ដែលទាក់ទងនឹងការប្រកាស ឬតាមហេតុការណ៍ជាក់ស្តែងលើសំណើផ្នែកសំភារៈគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់ដ៏ទៃទៀតតាមលក្ខណៈបច្ចេកទេសបរិស្ថាននៅពេល គេមានមូលហេតុគួរអោយទុកចិត្តថា សំណល់មានបញ្ហានេះមិនអាចគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសបរិស្ថានបាន ។ ការចំណាយលើការពិនិត្យពិច័យនេះមិនមែនជាបន្ទុករបស់លេខាធិការដ្ឋានឡើយ ។

ញ- ជួយភាគីនិមួយៗតាមសំណើ ស្តីពីអត្តសញ្ញាណកម្មនៃការដឹកជញ្ជូនខុសច្បាប់ និងផ្សព្វផ្សាយជាបន្ទាន់ដល់ភាគីពាក់ព័ន្ធ អំពីពត៌មានដែលទទួលបានពីការដឹកជញ្ជូនខុសច្បាប់ ។

ដ- សហការជាមួយភាគីនិមួយៗ អង្គការអន្តរជាតិ និងអង្គភាពពាក់ព័ន្ធនានា ក្នុងការផ្តល់អ្នកឯកទេស និងសំភារៈបច្ចេកទេស សំរាប់ជាប្រយោជន៍ក្នុងការជួយជាបន្ទាន់ដល់ប្រទេសដែលកំពុងមានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារសំណល់ ។

ឋ- ការបែងចែកតួនាទីផ្សេងៗនេះ តាមគោលបំណងរបស់អនុសញ្ញា ក៏ដូចជាការកំណត់របស់អង្គសន្និសិទ្ធភាគីដែរ ។

២- តួនាទីរបស់លេខាធិការដ្ឋាន នឹងត្រូវអនុវត្តដោយកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ ផ្អែកលើ

មូលដ្ឋានបណ្តោះអាសន្ន រហូតដល់ចុងបញ្ចប់អង្គប្រជុំលើកទីមួយរបស់អង្គសន្និសិទ្ធភាគី ដែលប្រារព្ធធ្វើឡើងអនុលោមតាមមាត្រាទី ១៥ ។

៣- នៅក្នុងអង្គប្រជុំលើកទីមួយរបស់ភាគី អង្គសន្និសិទ្ធភាគីត្រូវចាត់តាំងលេខាធិការដ្ឋាន មកពីក្នុងចំណោមអង្គការនៃអន្តររដ្ឋាភិបាល ដែលបានចុះហត្ថលេខាស្ម័គ្រចិត្ត ដើម្បីទទួលអនុវត្តតំណែងលេខាធិការដ្ឋានតាមអនុសញ្ញានេះ ។ នៅក្នុងអង្គប្រជុំនេះ អង្គសន្និសិទ្ធភាគីក៏ត្រូវវាយតំលៃលើការអនុវត្តន៍តួនាទីរបស់លេខាធិការដ្ឋានស្តីទីដែរ ជាពិសេសចំពោះសេចក្តីចែងនៅក្នុងវគ្គទី ១ នៃមាត្រានេះ និងដោះស្រាយសំរេចនៅពេលមានរចនាសម្ព័ន្ធត្រឹមត្រូវសំរាប់មុខតំណែងនេះ ។

## មាត្រាទី ១៧
## ការធ្វើវិសោធនកម្មអនុសញ្ញា

១- ភាគីនិមួយៗ អាចធ្វើសំណើក្នុងការធ្វើវិសោធនកម្មអនុសញ្ញានេះ ហើយភាគីដែលពាក់ព័ន្ធ នឹងកិច្ចព្រមព្រៀង មានសិទ្ធស្នើសុំក្នុងការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនោះ ។ ការធ្វើវិសោធនកម្មទាំងពីរខាងលើនេះ ត្រូវគិតគូពិចារណាអោយបានល្អិតល្អន់លើ អ៊ីនធ័រ អាលីយ៉ា (Inter-alia) ដែលទាក់ទងនឹងវិទ្យាសាស្ត្រ និងបច្ចេកទេស ។

២- ការធ្វើវិសោធនកម្មអនុសញ្ញានេះ ត្រូវតែមានការទទួលយល់ព្រមពីអង្គប្រជុំរបស់អង្គសន្និសិទ្ធភាគី ។ ការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀង ត្រូវតែមានការឯកភាពពីអង្គប្រជុំរបស់ភាគី ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង ។ រាល់លិខិតស្នើសុំធ្វើវិសោធនកម្មចំពោះអនុសញ្ញា និងកិច្ចព្រមព្រៀង នឹងត្រូវផ្ញើរជូនភាគីនិមួយៗតាមរយៈលេខាធិកាដ្ឋានក្នុងរយៈពេល ៦ខែ មុនពេលចាប់ផ្តើមបើកអង្គប្រជុំ ។ លេខាធិកាដ្ឋានក៏ត្រូវផ្សព្វផ្សាយផងដែរ អំពីសំណើធ្វើវិសោធនកម្ម ដល់ហត្ថលេខីនៃអនុសញ្ញានេះ សំរាប់ជាពត៌មាន ។

៣- ភាគីនិមួយៗ ត្រូវធ្វើការប្រឹងប្រែងដើម្បីសំរេចដល់ការយល់ព្រម លើសំណើសុំធ្វើវិសោធនកម្មនៅក្នុងអនុសញ្ញានេះដោយមតិទូទៅ ។ បើសិនការប្រឹងប្រែងនេះ មិនឈានដល់ការឯកភាពទេ មធ្យោបាយចុងក្រោយគឺការបោះឆ្នោតដើម្បីទទួលអនុមតិទៅលើសំលេងបីភាគបួននៃវត្តមានរបស់ភាគីនៅក្នុងអង្គសន្និសិទ ។ ហើយនឹងត្រូវបានរៀបចំដាក់ស្នើដោយលេខាធិការដ្ឋាន ចំពោះភាគីនិមួយៗ ដើម្បីទទួលការអនុម័ត ការឯកភាព ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រមរបស់ភាគីនិមួយៗ ។

៤- និតិវិធីដែលបានបញ្ជាក់ក្នុងវគ្គទី ៣ ខាងលើនេះ ត្រូវអនុវត្តចំពោះការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងណាមួយ លើកលែងតែសំលេងពីរភាគបីរបស់ភាគី ឯកភាពលើគោលការណ៍បច្ចុប្បន្នមទាំងការបោះឆ្នោតនៅក្នុងអង្គប្រជុំនឹងមានលក្ខណៈគ្រប់គ្រាន់ដល់ការអនុម័តរបស់គេ ។

៥- រាល់ឯកសារនៃការធ្វើវិសោធនកម្មទាំងឡាយទាក់ទងនឹងការសច្ចានុម័ត ការអនុញ្ញាត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រម នឹងត្រូវបានតំកល់ទុកនៅទីស្នាក់ការលេខាធិការដ្ឋាន ។ ការធ្វើវិសោធនកម្ម ដែលបានទទួលការអនុម័ត អនុលោមតាមការចែងនៅក្នុងវគ្គទី ៣ ឬទី ៤

ខាងលើ នឹងចូលជាធរមានក្រោយរយៈពេល ៩០ថ្ងៃ បន្ទាប់ពីទទួលបានលិខិតពីលេខាធិការដ្ឋាន ទាក់ទងនឹង ការសច្ចានុម័ត ការអនុញ្ញាត្ត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រមដោយមាន សំលេង គាំទ្របីភាគបួនពីភាគី លើការធ្វើវិសោធនកម្មចំពោះអនុសញ្ញា និងយ៉ាងតិចពីរភាគបី ចំពោះកិច្ចព្រមព្រៀង ។ ការធ្វើវិសោធនកម្មនឹងចូលជាធរមាន សំរាប់ភាគីទាំងអស់ក្នុងរយៈ ពេល ៩០ថ្ងៃ បន្ទាប់ពីភាគីបានដាក់ឱ្យពិនិត្យនូវឯកសារ ការធ្វើវិសោធនកម្មដែលមានការ សច្ចានុម័ត ការអនុញ្ញាត ការបញ្ជាក់ជាផ្លូវការ ឬការទទួលយល់ព្រម ។

៦- គោលបំណងរបស់មាត្រានេះ ពាក្យ ភាគីបច្ចុប្បន្ន និងការបោះឆ្នោត មានន័យថាភាគីដែល មានវត្តមានបច្ចុប្បន្ន និងការផ្តល់សំលេងគាំទ្រ ឬប្រឆាំង ។

## មាត្រាទី ១៨
## ការទទួលយល់ព្រម និងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ

១- ឧបសម្ព័ន្ធនៅក្នុងអនុសញ្ញានេះ ឬនៅក្នុងកិច្ចព្រមព្រៀងណាមួយ នឹងត្រូវបង្កើតបានជាផ្នែករួមផ្សំ នៃអនុសញ្ញា ឬកិច្ចព្រមព្រៀងនេះនៅក្នុងករណីដែលមិនបានចែងឱ្យខុសពីនេះ ឬក្នុងករណី ដែលមានសេចក្តីយោងទៅនឹងអនុសញ្ញានេះ ឬកិច្ចព្រមព្រៀងនៃឧបសម្ព័ន្ធរួមផ្សំដំណាលគ្នា នឹង ការយោងទៅនឹងឧបសម្ព័ន្ធនានា ។ ឧបសម្ព័ន្ធនេះត្រូវបានកំរិតទៅតាមបញ្ហាវិទ្យាសាស្ត្រ បច្ចេកទេស និងរដ្ឋបាល ។

២- លើកលែងតែមានចែងនៅក្នុងកិច្ចព្រមព្រៀងណាមួយ ចំពោះឧបសម្ព័ន្ធនោះ បើមិនដូច្នោះទេ នីតិវិធីខាងក្រោម នឹងត្រូវអនុវត្តទៅតាមសំណើ ទៅតាមការអនុម័ត និងត្រូវចាត់ចូលជាធរមាន ដោយបន្ថែមឧបសម្ព័ន្ធទៅលើអនុសញ្ញានេះ ឬទៅលើកិច្ចព្រមព្រៀង ។

- ក- ឧបសម្ព័ន្ធនៅក្នុងអនុសញ្ញា និងកិច្ចព្រមព្រៀងនេះ ត្រូវបានស្នើ និងធ្វើការអនុម័តអនុលោម ទៅតាមនីតិវិធី ដែលបានចែងនៅក្នុងមាត្រាទី ១៧ វគ្គទី ២ ទី ៣ និងទី ៤ ។
- ខ- ភាគីណាមួយ ដែលមិនអាចទទួលយល់ព្រមពីការសុំបន្ថែមឧបសម្ព័ន្ធនៅក្នុងអនុសញ្ញានេះ ឬនៅក្នុងកិច្ចព្រមព្រៀងណាមួយ នោះភាគីត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដល់ទីស្នាក់ការ ផ្ទុកឯកសាររបស់លេខាធិការដ្ឋាន ក្នុងរយៈពេល ៦ខែ គិតចាប់ពីពេលដែលទីស្នាក់ការ ធ្វើការទំនាក់ទំនងទៅភាគីនានាដើម្បីទទួលការអនុម័ត ។ ទីស្នាក់ការផ្ទុកឯកសាររបស់លេខា ធិការដ្ឋានត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីនិមួយៗ នៅពេលបានទទួលសេចក្តីរាយការណ៍ នោះ។ ភាគីនិមួយៗអាចផ្លាស់ប្តូរជំហររបស់ខ្លួន ស្តីពីការជំទាស់ទៅលើសេចក្តីប្រកាសកន្លង មកដោយទទួលយល់ព្រមវិញ ហើយឧបសម្ព័ន្ធនឹងចូលជាធរមានសំរាប់ភាគីទាំងអស់ ។
- គ- ក្នុងរយៈពេល ៦ខែផុតកំណត់បន្ទាប់ពីពេលដែលទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋាន បានបញ្ជូនដំណឹង នោះឧបសម្ព័ន្ធនឹងមានប្រសិទ្ធភាពសំរាប់ភាគីទាំងអស់ក្នុងអនុសញ្ញានេះ ឬសំរាប់កិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗ ដែលមិនបានដាក់ស្នើសេចក្តីប្រកាសស្របតាមសេចក្តី ចែងនៃវគ្គ (ខ) ខាងលើ ។

៣- រាល់សំណើ លើការអនុម័តនិងការចូលជាធរមាន នៃការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធរបស់អនុសញ្ញានេះ ឬចំពោះកិច្ចព្រមព្រៀងផ្សេងៗ នឹងជាប្រធានបទសំខាន់សំរាប់ទំរង់ការតែមួយដូចគ្នានឹងសំណើលើការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធចំពោះអនុសញ្ញា ឬចំពោះកិច្ចព្រមព្រៀង ។ រាល់ការធ្វើវិសោធនកម្មឧបសម្ព័ន្ធ ត្រូវគិតគូលើ អ៊ីនធ័រ អាលីយ៉ា ដែលទាក់ទងនឹងការពិចារណាទៅលើវិទ្យាសាស្ត្រ និងបច្ចេកទេសសង្គម ។

៤- បើសិនការបន្ថែមឧបសម្ព័ន្ធ ឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធ មានការពាក់ព័ន្ធជាមួយនឹងអនុសញ្ញានេះឬកិច្ចព្រមព្រៀងផ្សេងៗ នោះការបន្ថែម ឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធ មិនអាចនឹងចូលជាធរមាន រហូតដល់ការធ្វើវិសោធនកម្មចំពោះអនុសញ្ញាឬកិច្ចព្រមព្រៀងនេះចូលជាធរមានសិន ។

## មាត្រានី ១៩
## តស្ថុតាទ

ភាគីណាមួយ ដែលមានហេតុផលគួរអោយទុកចិត្តថា មានភាគីផ្សេងទៀតដែលកំពុង ឬបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចខ្លួនដែលមានចែងក្នុងអនុសញ្ញានេះ ភាគីនោះអាចរាយការណ៍ជូនលេខាធិការដ្ឋាន និងក្នុងព្រឹត្តិការណ៍ជាមួយគ្នានេះ ត្រូវរាយការណ៍ផ្ទាល់ ឬដោយប្រយោលដល់លេខាធិការដ្ឋានជាបន្ទាន់ អំពីភាគីដែលបានប្រព្រឹត្តបំពាននឹងអនុសញ្ញា ។ លេខាធិការដ្ឋាន នឹងត្រូវដាក់ស្នើរាល់ពត៌មានពាក់ពន្ធ័ទាំងអស់ ទៅគ្រប់ភាគីនីមួយៗដើម្បីពិនិត្យ ។

## មាត្រានី ២០
## ដំណោះស្រាយនៃវិវាទ

១- ក្នុងករណីមានជំលោះរវាងគូភាគីទាំងឡាយ តាមរយៈការបកស្រាយ ការអនុវត្តន៍ផ្នែកទៅតាមអនុសញ្ញានេះឬកិច្ចព្រមព្រៀង ភាគីនិមួយៗត្រូវរកវិធីដោះស្រាយជំលោះ តាមរយៈការចរចា ឬមធ្យោបាយសំរុះសំរួលណាមួយ តាមការជ្រើសរើសរបស់គេ ។

២- បើសិនភាគីពាក់ព័ន្ធ មិនអាចដោះស្រាយជំលោះរបស់គេ តាមរយៈមធ្យោបាយដែលបញ្ជាក់ក្នុងវគ្គទី ១ នៃមាត្រានេះ ហើយបើភាគីនៅតែបន្តជំលោះ ភាគីទាំងនោះត្រូវដាក់ជូនតុលាការអន្តរជាតិ ឬដាក់ជូនអាជ្ញាកណ្តាលដែលស្ថិតក្នុងលក្ខខ័ណ្ឌបានចែងក្នុងឧបសម្ព័ន្ធទី ៦ ហើយដែលមានចែងពីអាជ្ញាកណ្តាល ។ ទោះបីពុំបានទទួលជោគជ័យក្នុងការស្វែងរកការឯកភាពរួមលើការដាក់អោយពិនិត្យជំលោះទៅតុលាការអន្តរជាតិ ឬទៅអាជ្ញាកណ្តាលក្តី នោះមិនត្រូវអោយភាគីទាំងនោះរួចផុតពីការទទួលខុសត្រូវក្នុងការបន្តស្វែងរកដំណោះស្រាយជំលោះតាមមធ្យោបាយស្របតាមវគ្គទី ១ ឡើយ ។

៣- នៅពេលកំពុងធ្វើការសច្ចានុម័ត ការទទួលយល់ព្រម ការអនុញ្ញាត្ត ការបញ្ជាក់ជាផ្លូវការ ឬកំពុងឯកភាព ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួម អាចធ្វើការប្រកាសទទួលស្គាល់

ជាផ្លូវការ ដូចជាភាពចាំបាច់នៃអ៊ីសូហ្វាកតូ ( Ipso Facto ) និងពុំចាំបាច់នូវការឯកភាពពិសេសទាក់ទងនឹងភាគីដែលមានកាតព្វកិច្ចដូចគ្នា :

ក- ការដាក់ជូនទៅតុលាការអន្តរជាតិនូវបញ្ហាជម្លោះ ដើម្បីធ្វើការវិនិច្ឆ័យពិនិត្យ

ខ- ឬទៅអាជ្ញាកណ្តាល អនុលោមតាមនិតិវិធី ដែលមានចែងក្នុងឧបសម្ព័ន្ធទី ៦ ។

សេចក្តីប្រកាសនេះ នឹងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ដែលនឹងជូនបន្តដល់ភាគីឯទៀត ។

## មាត្រាទី ២១
## ការចុះហត្ថលេខា

អនុសញ្ញានេះ ត្រូវបានបើកដំណើរការចុះហត្ថលេខាដោយតំណាងប្រទេស ដោយណាមីប៊ីយ៉ា (Namibia) ដែលជាតំណាងឱ្យក្រុមប្រឹក្សាអង្គការសហប្រជាជាតិ សំរាប់ណាមីប៊ីយ៉ា (Namibia) និងដោយអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ក្នុងទីក្រុងបាសែល នៅនាយកដ្ឋានសហព័ន្ធកិច្ចការបរទេសនៃប្រទេសស្វីសក្នុងទីក្រុង Berne កាលពីថ្ងៃទី ២៣ ខែ មីនា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨៩ និងនៅទីស្នាក់ការអង្គការសហប្រជាជាតិប្រចាំទីក្រុងញូវយ៉កពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ១៩៨៩ ដល់ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩០ ។

## មាត្រាទី ២២
## ការសច្ចានុម័ត ការព្រមព្រៀង ការបញ្ជាក់ ឬការអនុម័តជាផ្លូវការ

១- អនុសញ្ញានេះ នឹងជាប្រធានបទសំខាន់ចំពោះការធ្វើសច្ចានុម័ត ការព្រមព្រៀង ឬការអនុម័តដោយណាមីប៊ីយ៉ា ( Namibia ) ដែលជាតំណាងក្រុមប្រឹក្សាអង្គការសហប្រជាជាតិសំរាប់ ណាមីប៊ីយ៉ា ( Namibia ) និងចំពោះការបញ្ជាក់ ឬអនុម័តជាផ្លូវការ ដោយអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ។ ចំពោះឯកសារស្តីពីការធ្វើសច្ចានុម័ត ការព្រមព្រៀង ការបញ្ជាក់ជាផ្លូវការឬការអនុម័ត នឹងត្រូវតំកល់ទុកនៅក្នុងទីស្នាក់ការផ្ទុកឯកសារលេខាធិការដ្ឋាន ។

២- យោងតាមវគ្គទី ១ ខាងលើ អង្គការណាមួយដែលក្លាយជាភាគីក្នុងអនុសញ្ញា ដោយពុំមែនជាសមាជិករដ្ឋាភិបាលណាមួយ ភាគីនោះនឹងត្រូវបានកំណត់កាតព្វកិច្ចទាំងអស់ ដោយអនុសញ្ញានេះ ។ ក្នុងករណីដែលអង្គការទាំងនេះ ជាសមាជិករដ្ឋាភិបាល ហើយបានក្លាយទៅជាភាគីនៃអនុសញ្ញា នោះអង្គការនិងសមាជិករដ្ឋាភិបាលត្រូវធ្វើការសំរេចចិត្ត ទៅលើការទទួលខុសត្រូវចំពោះការបំពេញកាតព្វកិច្ចរបស់ខ្លួន តាមការកំណត់របស់អនុសញ្ញា ។
ក្នុងករណីដូចគ្នានេះ អង្គការនិងសមាជិករដ្ឋាភិបាល នឹងមិនត្រូវផ្តល់អំណាចដល់ការអនុវត្តន៍សិទ្ធិចំពោះអនុសញ្ញានេះឡើយ ។

៣- យោងតាមវគ្គទី ១ ខាងលើ អង្គការនានា ត្រូវរាយការណ៍ពីការបញ្ជាក់ ឬការអនុញ្ញាតទៅលើសមត្ថភាពរបស់គេ ចំពោះការងារដែលកំណត់ដោយអនុសញ្ញា ។ អង្គការនេះ ក៏ត្រូវរាយការណ៍

ទៅទីស្នាក់ការផ្ទុកឯកសាររបស់លេខាធិការដ្ឋាន ថាតើនរណាដែលជាអ្នកទទួលខុសត្រូវ លើការរាយការណ៍ដល់ភាគី អំពីការកំណត់ចំពោះទំហំសមត្ថភាពរបស់គេ ។

## មាត្រាទី ២៣

## ការចូលរួម

១- អនុសញ្ញានេះ នឹងបើកចំហរចំពោះការចូលរួមពីប្រទេសនិមួយៗមកពីណាមីប៊ីយ៉ា (Namibia) ដែលតំណាងអោយក្រុមប្រឹក្សាអង្គការសហប្រជាជាតិសំរាប់ណាមីប៊ីយ៉ា និងអង្គការដែលមានគោលនយោបាយ រឺសេដ្ឋកិច្ចរួមបន្ទាប់ពីថ្ងៃដែលអនុសញ្ញានេះបានបញ្ចប់ការចុះហត្ថលេខាមក ។ ហើយឯកសារស្តីពីការចូលរួមនេះ នឹងត្រូវតំកល់ទុកនៅលេខាធិការដ្ឋាន ។

២- យោងតាមវគ្គទី ១ ខាងលើ នៅក្នុងឯកសារស្តីពីការចូលរួម អង្គការត្រូវរាយការណ៍អំពីទំហំសមត្ថភាព ចំពោះការងារដែលបានគ្រប់គ្រងដោយអនុសញ្ញា ។ ទន្ទឹមនឹងនេះដែរ អង្គការក៏ត្រូវបញ្ជាក់ប្រាប់ដល់ទីស្នាក់ការលេខាធិការដ្ឋាន អំពីបំលាស់ប្តូរសំខាន់ៗនៅក្នុងទំហំសមត្ថភាពរបស់គេ ។

៣- សេចក្តីចែងនៅក្នុងមាត្រាទី ២២ វគ្គទី ២ ត្រូវអនុវត្តចំពោះអង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ដែលទទួលយល់ព្រមចំពោះអនុសញ្ញានេះ ។

## មាត្រាទី ២៤

## សិទ្ធិបោះឆ្នោត

១- លើកលែងតែសេចក្តីចែងនៅក្នុងវគ្គទី ២ នៃមាត្រានេះ ក្រៅពីនោះភាគីនិមួយៗដែលបានចុះកិច្ចសន្យាចូលជាសមាជិករបស់អនុសញ្ញានេះ ត្រូវមានសិទ្ធចូលរួមការបោះឆ្នោតបានម្តង ។

២- នៅក្នុងបញ្ហាសមត្ថភាពដូចមានចែងក្នុងមាត្រាទី ២២ វគ្គទី៣ និងមាត្រាទី២៣ វគ្គទី២ អង្គការដែលមានគោលនយោបាយ ឬសេដ្ឋកិច្ចរួម ត្រូវប្រើប្រាស់សិទ្ធរបស់គេសំរាប់បោះឆ្នោតជ្រើសរើសសមាជិកដែលមានចំនួនស្មើនឹង ចំនួនសមាជិករដ្ឋាភិបាលដែលជាភាគីរបស់អនុសញ្ញា ឬរបស់កិច្ចព្រមព្រៀង ។ ផ្ទុយទៅវិញ អង្គការនេះមិនត្រូវប្រើប្រាស់សិទ្ធរបស់គេដើម្បីបោះឆ្នោតទេ បើសិនសមាជិករដ្ឋាភិបាលរបស់គេ ប្រើប្រាស់ត្រឹមតែច្បាប់របស់គេប៉ុណ្ណោះ។

## មាត្រាទី ២៥

## ការចូលជាធរមាននៃអនុសញ្ញា

១- អនុសញ្ញានេះនឹងចូលជាធរមានក្រោយរយៈពេល ៩០ថ្ងៃបន្ទាប់ពីថ្ងៃដែលបានដាក់ជូនឯកសារទី ២០ (twentieth instrument) ស្តីពីការសច្ចានុម័ត ការទទួលយក ការបញ្ជាក់ជាផ្លូវការការអនុញ្ញាត្ត ឬការទទួលយល់ព្រម ។

២- រាល់ប្រទេសនិមួយៗឬអង្គការដែលមានគោលនយោបាយឬសេដ្ឋកិច្ចរួម ដែលទទួលយកការអនុម័ត ការបញ្ជាក់ជាផ្លូវការ ឬក៏ទទួលយល់ព្រមចំពោះអនុសញ្ញានេះ បន្ទាប់ពីថ្ងៃដែលបានដាក់ជូននូវឯកសារទី ២០ លើការសច្ចានុម័ត ការទទួលយក ការបញ្ជាក់ជាផ្លូវការ ការអនុញ្ញាត្ត ឬការទទួលយល់ព្រម នឹងចូលជាធរមានក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់នោះមក ។

៣- តាមគោលបំណងនៃសេចក្តីចែងក្នុងវគ្គទី ១ និងទី ២ ខាងលើ អង្គការដែលមាននយោបាយ ឬសេដ្ឋកិច្ចរួម ដែលបានដាក់ឯកសារណាមួយ នឹងមិនត្រូវបានយកមកបញ្ចូលបន្ថែមចំពោះការដាក់ឯកសារពាក់ព័ន្ធដែលធ្វើឡើងដោយសមាជិករដ្ឋាភិបាលនៃអង្គការដូចគ្នាឡើយ ។

## មាត្រាទី ២៦
## ការត្រៀមទុកនិងការប្រកាស

១- ការត្រៀមទុក ឬការលើកលែងពុំមានចែងក្នុងអនុសញ្ញានេះឡើយ ។

២- វគ្គទី ១ នៃមាត្រានេះ មិនធ្វើអោយរាំងស្ទះដល់ការធ្វើសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍របស់ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួមណាមួយ នៅពេលចុះហត្ថលេខា ធ្វើសច្ចានុម័ត ទទួលយក អនុញ្ញាត្ត ការបញ្ជាក់ជាផ្លូវការ ឬធ្វើការទទួលយល់ព្រមចំពោះអនុសញ្ញានេះ ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងចំណោមច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសឬអង្គការនយោបាយសេដ្ឋកិច្ចរួម គឺមានលក្ខណៈសមស្របនឹងការចែងនៃអនុសញ្ញា ដោយផ្តល់នូវសេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍ទៅតាមពាក្យសុំរបស់គេ សំដៅលើការបដិសេធ ឬផ្លាស់ប្តូរលទ្ធផលស្របច្បាប់ដូចមានចែងក្នុងអនុសញ្ញា ។

## មាត្រាទី ២៧
## ការដកពាក្យចេញពីសមាជិកភាព

ក្រោយរយៈពេលបីឆ្នាំ បន្ទាប់ពីថ្ងៃចូលជាភាគីពេញសិទ្ធនៃអនុសញ្ញា ភាគីនិមួយៗអាចដកពាក្យចេញពីសមាជិកភាពរបស់អនុសញ្ញានេះវិញនៅពេលណាមួយក៏បាន ដោយគ្រាន់តែសរសេរបញ្ជាក់ជាលាយលក្ខណ៍អក្សរ ជូនដំណឹងទៅទីស្នាក់ការតំកល់ឯកសាររបស់លេខាធិការដ្ឋាន ។

## មាត្រាទី ២៨
## ទីស្នាក់ការតំកល់ឯកសារ

អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ នឹងមាននាទីជាទីស្នាក់ការតំកល់ឯកសាររបស់អនុសញ្ញានិងកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធ ។

## មាត្រានី ២៩
## អត្ថបទដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់

អត្ថបទជាភាសារដើមដូចជា ភាសារអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានក្នុងអនុសញ្ញានេះ នឹងចាត់ទុកជាភាសារផ្លូវការត្រឹមត្រូវដូចគ្នា ។

ការចុះហត្ថលេខាខាងក្រោមជាសាក្សីឬតឹកតាងបញ្ជាក់ថា មានសិទ្ធអំណាចត្រឹមត្រូវនិងពេញលេញ បន្ទាប់ពីការចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅ ថ្ងៃ ខែ ឆ្នាំ

## ឧបសម្ព័ន្ធទី ១
## ប្រភេទសំណល់ដែលត្រូវត្រួតពិនិត្យ

**ប្រភពសំណល់**

១- សំណល់វេជ្ជសាស្ត្រ ដែលបានមកពីការព្យាបាល និងការវះកាត់ជំងឺនៅក្នុងមន្ទីរពេទ្យ គ្លីនិក និងមជ្ឈមណ្ឌលវេជ្ជសាស្ត្រ ។

២- សំណល់ដែលបានមកពីផលិតផល និងដំណើរការរៀបចំផលិតឱសថ

៣- សំណល់ឱសថ ថ្នាំគ្រាប់ និងថ្នាំចាក់

៤- សំណល់ដែលបានមកពីផលិតផល ការផ្សំ និងការប្រើប្រាស់ថ្នាំសំរាប់ការបំបែកធាតុគីមី ជីវៈ និង ឱសថដែលបានមកពីរុក្ខជាតិ ។

៥- សំណល់ដែលបានមកពីការផលិត ការផ្សំ និងការប្រើប្រាស់ជាតិគីមីដើម្បីការពារសាច់ឈើ ។

៦- សំណល់ដែលបានមកពីផលិតផល ការផ្សំ និងការប្រើប្រាស់សារធាតុសរីរាង្គរំលាយ ។

៧- សំណល់ដែលបានមកពីការដុតកំដៅ និងដំណើរការធ្វើឱ្យលោហៈមានភាពរឹង ដែលផ្ទុកដោយសារធាតុគីមីស្យានីត ( cyanides ) ។

៨- សំណល់ដែលបានពីសារធាតុប្រេងដែលមិនអាចប្រើប្រាស់បាន

៩- សំណល់ប្រេង ទឹក អ៊ីដ្រូកាបួន ល្បាយទឹក និងថ្នាំលាប

១០- សំណល់ដែលបានមកពីសារធាតុផ្សេងៗ និងភាគល្អិតនានាដែលផ្ទុក ប៉ូលីក្លរ៉ូបេនហ្វេណីល (PCBs) ប៉ូលីក្លរ៉ូតេផ្វេណីល (PCTs) និងប៉ូលីប្រូមីនបីផ្វេណីល (PBBs)

១១- សំណល់ជ័រដែលបានមកពីការស្លកែច្នៃ ការបិតចំហេះ និងការធ្វើប្រតិកម្មពីរ៉ូលីទិច (Pyrolytic)

១២- សំណល់ដែលបានមកពីផលិតផល ការផ្សំ និងការប្រើប្រាស់ទឹកខ្មៅ ល័ក្ខណ៍ ជាតិពណ៌ ថ្នាំលាប ម្រ័ក្សណ៍ ថ្នាំរលោង ។

១៣- សំណល់ដែលបានមកពីផលិតផល ការផ្សំ និងការប្រើប្រាស់ជ័រឈើ ជ័រកៅស៊ូ ជ័របា្លស្ទិច ជ័រកាវ និងសារធាតុស្អិត ។

១៤- សំណល់សារធាតុគីមីថ្មីដែលពុំស្គាល់បានកកើតឡើងពីការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ឬសកម្មភាពបង្រៀន ដែលមានឥទ្ធិពលលើមនុស្ស ឬបរិស្ថាន ។

១៥- សំណល់ជាតិផ្ទុះដែលអាចកើតឡើងដោយដោយធម្មជាតិ មិនមែនជាប្រធានបទចំពោះច្បាប់ដទៃទៀត ។

១៦- សំណល់ដែលបានមកពីផលិតផល ការផ្សំ និងការប្រើប្រាស់សារធាតុគីមីសំរាប់លាងរូបថត និងការប្រើប្រាស់សំភារៈផ្សេងៗក្នុងដំណើរការនោះ ។

១៧- សំណល់ដែលជាលទ្ធផលនៃការធ្វើប្រព្រឹត្តិកម្មផ្ទៃខាងលើរបស់លោហៈ និងផ្លាស្ទិច ។

១៨- សំណល់ដែលបានមកពីដំណើរការចាក់ចោលសំណល់ឧស្សាហកម្ម

**ធាតុផ្សំរបស់សំណល់**

១៩- លោហៈកាបូន(C)
២០- បេរីល្យូម (Be) និងសមាសធាតុរបស់វា
២១- ក្រូម (Cr)និងសមាសធាតុរបស់វា
២២- សមាសធាតុទង់ដែង (Cu)
២៣- សមាធាតុស័ង្កសី (Zn)
២៤- អាសេនិក (As) និងសមាសធាតុរបស់វា
២៥- សេលេញ៉ូម (Se) និងសមាសធាតុរបស់វា
២៦- កាត់មូម (Cd) និងសមាសធាតុរបស់វា
២៧- អង់ទីមន ( Sb ) និងសមាសធាតុរបស់វា
២៨- តេលុយរ្យូម (Te) និងសមាសធាតុរបស់វា ( Tellurium; Tellurium compounds)
២៩- បារ៉ត (Hg) និងសមាសធាតុរបស់វា
៣០- តាល់ល្យូម (Tl) និងសមាសធាតុរបស់វា (Thallium; Thallium compounds )
៣១- សំណ (Pb) និងសមាសធាតុរបស់វា
៣២- សមាសធាតុអសរីរាង្គភ្លុយអរីន លើកលែងតែកាល់ស្យូមភ្លុយអរីដ (Inorganic fluorine compoundss excluding calcium fluoride )
៣៣- ស្យាទីតអសរីរាង្គ ($CN^{-1}$)
៣៤- សូលុយស្យុងអាស៊ីត ឬអាស៊ីតស្ថិតក្នុងលក្ខណៈរឹង (Acidic solution or acids in solid form)
៣៥- សូលុយស្យុងបាស ឬសូលុយស្យុងបាសស្ថិតក្នុងលក្ខណៈរឹង (Basic solutions or bases in solid form )
៣៦- អាបេស្ត (ធូលី និងអំបោះ) (Asbestos)
៣៧- សមាសធាតុសរីរាង្គផូស្វរ (P)
៣៨- ស្យាទីតសរីរាង្គ (Organic cyanides)
៣៩- ផេណុល សមាសធាតុផេណុល រាប់បញ្ចូលទាំងក្លរ៉ូផេណុល
៤០- អេទែ (Ethers)
៤១- សរីរាង្គអាឡូសែនរំលាយ (Halogenated organic solvents)
៤២- អង្គធាតុរំលាយសរីរាង្គ លើកលែងតែសរីរាង្គអាឡូសែនរំលាយ ( Oranic Solvents excluding Halogenated Organic Solvents )
៤៣- កុងសែន្ទ នៃ ប៉ូលីក្លរីដ ឌីបែនស្សូហ្វ៊ុរ៉ាន ( Any congenor of polychlorinated dibenzofuran )
៤៤- កុងសែន្ទ នៃ ប៉ូលីក្លរីដ ឌីបែនហ្សូប៉ារ៉ា ឌីអុកស៊ីន ( Any congenor of polyclorinated dibenzo-p-dioxin )
៤៥- សមាសធាតុសរីរាង្គអាឡូសែន ក្រៅពីសមាសធាតុដែលទាក់ទងនៅក្នុងឧបសម្ព័ន្ធនេះ ដូចជា : (៣៩- ៤០ - ៤១ - ៤២ - ៤៣ - ៤៤ ) ។

## ឧបសម្ព័ន្ធ ២
## ប្រភេទសំណល់ដែលស្នើអោយមានការពិចារណាពិសេស

៤៦- សំណល់ដែលប្រមូលបានមកពីសំណល់ផ្ទះសម្បែង

៤៧- សំណល់ដែលបានមកពីការដុតសំណល់ផ្ទះសម្បែង

## ឧបសម្ព័ន្ធ ៣
## បញ្ជីឈ្មោះស្តីពីលក្ខណៈគ្រោះថ្នាក់នៃសំណល់

**ថ្នាក់ លេខសំគាល់ លក្ខណៈ**

១ $H_1$ **សារធាតុដែលអាចផ្ទុះ**

សំណល់ ឬសារធាតុផ្ទុះ គឺជាសារធាតុរឹង រាវ ឬសំណល់ (សមាសធាតុល្បាយ ឬសំណល់) ដែលមានលទ្ធភាពផលិតឧស្ម័ននៅក្នុងប្រតិកម្មគីមី នៅក្នុងសីតុណ្ហភាពមួយ សំពាធនិងនៅល្បឿនតែមួយ ដែលអាចបណ្តាលឱ្យអន្តរាយដល់អ្វីៗដែលនៅជុំវិញ ។

៣ $H_3$ **អង្គធាតុរាវដែលងាយឆេះ**

អង្គធាតុរាវងាយឆេះ ជាអង្គធាតុរាវ ឬល្បាយអង្គធាតុរាវ ឬអង្គធាតុរាវ ដែលមានអង្គធាតុរឹងនៅក្នុងល្បាយ ឬអណ្តែត (ឧទា : ថ្នាំលាប ថ្នាំរលោង ម្រ័ក្សណ៍ ដោយមិនរាប់បញ្ចូលសារធាតុ ឬសំណល់ ម្យ៉ាងទៀតការបែងចែក ចំណាត់ថ្នាក់ គឺផ្អែកលើប្រភេទគ្រោះថ្នាក់របស់វា) ដែលនៅសីតុណ្ហភាព ៦០$^0$c (តាមការសាកល្បង នៅពេលសាកល្បងបិទកែវ (closed cup) ឬ ៦៥,៦$^0$c នៅពេលសាកល្បង បើកកែវ (open cup) វាជាចំហាយដែលមិនអាចឆេះ) ។

៤.១ $H_{4.1}$ **អង្គធាតុរឹងដែលងាយឆេះ**

អង្គធាតុរឹង ឬសំណល់រឹង ឬសំណល់ផ្សេងៗ ក្រៅពីប្រភេទសំណល់ដែលអាចផ្ទុះ ហើយដែលអាចឆេះ ឬអាចបណ្តាលអោយឆេះដោយសារការកកិត ដែលស្ថិតក្នុងអំឡុងពេលដឹកជញ្ជូន ។

៤.២ $H_{4.2}$ **សារធាតុឬសំណល់ដែលអាចឆេះដោយខ្លួនឯង**

សារធាតុឬសំណល់ដែលអាចឆេះដោយខ្លួនឯង ក្នុងលក្ខខ័ណ្ឌធម្មតា ក្នុងពេលដឹកជញ្ជូន ឬឆេះឡើងដោយសារប៉ះនឹងខ្យល់ ។

៤.៣ $H_{4.3}$ **សារធាតុឬសំណល់ពេលប៉ះជាមួយទឹកបញ្ចេញជាឧស្ម័នដែលងាយឆេះ**

សារធាតុឬសំណល់ដែលធ្វើប្រតិកម្មជាមួយទឹក អាចក្លាយជាអង្គធាតុ

ឆេះដោយឯកឯង ឬជាឧស្ម័នដែលងាយឆេះក្នុងសភាពគ្រោះថ្នាក់ខ្លាំង ។

៥,១ $H_{5.1}$ **ការធ្វើអុកស៊ីដកម្ម**

សារធាតុឬសំណល់ ដែលមិនងាយឆេះ ហើយជាទូទៅអាចឆេះបាន នៅពេលមានប៉ះជាមួយអុកស៊ីសែន ឬជាមួយសារធាតុដ៏ទៃទៀត ។

៥,២ $H_{5.2}$ **អុកស៊ីដកម្មសរីរាង្គ**

សារធាតុសរីរាង្គឬសំណល់ដែលផ្ទុកទៅដោយសម្ព័ន្ធប៊ីវ៉ាឡង់ -o-o- ជាសារធាតុដែលអាចប្រែប្រួលដោយសារកំដៅ ដែលអាចរង exothermic ដោយការញែកធាតុខ្លួនឯង ។

៦,១ $H_{6.1}$ **ដែលពុល "សារធាតុធ្ងន់ធ្ងរ "**

សារធាតុឬសំណល់ដែលអាចបង្កអោយស្លាប់ រងរបួសធ្ងន់ធ្ងរឬបំផ្លាញសុខភាព បើសិនយើងលេបចូល ដកដង្ហើម ឬការប៉ះតាមស្បែក ។

៦,២ $H_{6.2}$ **សារធាតុចំលងរោគ**

សារធាតុ ឬកាកសំណល់ ដែលផ្ទុកដោយមីក្រូសារពាង្គកាយឬជាតិពុលដែលយើងស្គាល់ ឬសង្ស័យថាបានបង្ករអោយកើតជំងឺដល់សត្វ និងមនុស្សលោក ។

៨ $H_8$ **សារធាតុដែលបង្ករអោយច្រេះ**

សារធាតុឬសំណល់ដែលនឹងបង្ករការបំផ្លាញដោយប្រតិកម្មគីមី នៅពេលដែលប៉ះជាមួយជាលិកានៃសរីរាង្គមានជីវិត ឬក្នុងករណីដែលលេចជ្រាប រាល់សម្ភារៈនឹងត្រូវបំផ្លាញឬខូចខាត រឺឯឬមធ្យោបាយដឹកជញ្ជូនក៏អាចបង្កអោយមានគ្រោះថ្នាក់ផ្សេងៗដែរ ។

៩ $H_{10}$ **ការបញ្ចេញឧស្ម័នពុល នៅក្នុងខ្យល់ ឬទឹក**

សារធាតុឬសំណល់ដែលអាចបញ្ចេញឧស្ម័នពុល ក្នុងកំរិតគ្រោះថ្នាក់ខ្ពស់នៅពេលមានប្រតិកម្មជាមួយទឹកឬខ្យល់ ។

៩ $H_{11}$ **ដែលពុល "សារធាតុរលាយយូរនិងរ៉ាំរ៉ៃ "**

សារធាតុឬសំណល់បណ្តាលឱ្យមានជំងឺយូរអង្វែងនិងរ៉ាំរ៉ៃ រួមទាំងជំងឺមហារីក នៅពេលដែលមានការប៉ះពាល់តាមរយៈការ ដកដង្ហើម ការលេបចូលតាមមាត់ ឬការជ្រាបចូលតាមស្បែក ។

៩ $H_{12}$ **អេកូទីសសាស្ត្រ Ecotoxic**

សារធាតុឬសំណល់ដែលនឹងបង្កឱ្យមានការប៉ះពាល់បរិស្ថានភ្លាមៗ ឬក្នុងពេលអនាគតយូរអង្វែងបណ្តាលមកពីបណ្តុំជីវៈ ប្រព័ន្ធប៊ីយ៉ូទិច (biotic systems) ។

៩ $H_{13}$ បន្ទាប់ពីការបោះបង់ចោលទិន្នផលសារធាតុណាមួយ វាអាចបណ្តាលឱ្យមានបញ្ហាផ្សេងៗ ដូចមានរៀបរាប់ពីប្រភេទលក្ខណៈខាងលើ

**ការពិភាក្សា**

សុក្ខានុពលគ្រោះថ្នាក់របស់ប្រភេទសំណល់ នៅមិនទាន់ចងក្រងជាឯកសារឱ្យបានគ្រប់គ្រាន់ទេ ។ ការវិភាគកំណត់ឱ្យច្បាស់លាស់ពីចំនួនគ្រោះថ្នាក់នៃសំណល់មិនអាចធ្វើបានឡើយ ។ ការស្រាវជ្រាវត្រូវធ្វើឡើងឱ្យល្អិតល្អន់ដើម្បីកំណត់ពីលក្ខណៈគ្រោះថ្នាក់ ដែលមានទៅលើមនុស្សឬបរិស្ថានដោយសារប្រភេទសំណល់ទាំងនេះ ។ ការវិភាគទៅតាមក៏រិតស្តង់ដាកំណត់ អាចធ្វើអោយសារធាតុនិងរូបធាតុពុំមានលក្ខណៈបំពុល ។ មានប្រទេសជាច្រើនបានពង្រីកការវិភាគរបស់ខ្លួន ដែលអាចអនុវត្តក្នុងបញ្ជីរូបធាតុ ក្នុងឧបសម្ព័ន្ធទី ១ ។

## ឧបសម្ព័ន្ធទី ៤

## ដំណើរការបោះបង់ចោលសំណល់

### ក. ដំណើរការដែលមិនបង្កអោយមានលទ្ធភាពក្នុងការកែច្នៃ ការទាញយក ការចំរាញ់ ការប្រើប្រាស់ឡើងវិញដោយផ្ទាល់ ឬការប្រើប្រាស់ជំនួស ៗ

នៅវគ្គ "ក" នេះបានលើកឡើងពីរាល់ការអនុវត្តន៍ លើការចាក់សំណល់ចោលទៅតាមការប្រតិបត្តិជាក់ស្តែង ។

$D_1$ ចាក់ចោលទៅក្នុងឬទៅលើដី (ឧទាហរណ៍: ទីលានទុកដាក់សំណល់ )

$D_2$ ការធ្វើប្រព្រឹត្តិកម្មជាមួយដី (ការបំបែកធាតុជីវៈនៃអង្គធាតុរាវឬសំណល់កករភក់ ដែលចាក់ចោលទៅក្នុងដី )

$D_3$ ការទុកដាក់សំណល់ដោយកប់អោយជ្រៅ (ការចាក់បញ្ចូលទៅក្នុងអណ្តូង )

$D_4$ ការទុកដាក់នៅផ្ទៃខាងលើ (ការទុកដាក់សំណល់រាវ ឬសំណល់ភក់នៅក្នុងរណ្តៅ ត្រពាំង ឬនៅក្នុងដៃសមុទ្រ )

$D_5$ ទីលានទុកដាក់សំណល់ពិសេស (បានដាក់ជាជួរដាច់ៗពីគ្នា មានគំរបបិទជិត និងដាក់អោយដាច់ពីគ្នា ដោយគិតគូពីហេតុប៉ះពាល់បរិស្ថាន ។

$D_6$ ការបោះបង់ចោលទៅក្នុងទឹក លើកលែងសមុទ្រនិងមហាសមុទ្រ

$D_7$ ការបោះបង់ចោលទៅក្នុងសមុទ្រនិងមហាសមុទ្រ រាប់បញ្ចូលទាំងជ្រលងសមុទ្រ (sea-bed) ទៀតផង ។

$D_8$ ការធ្វើប្រព្រឹត្តិកម្មជីវៈ មិនបានបញ្ជាក់អោយបានច្បាស់លាស់នៅក្នុងឧបសម្ព័ន្ធនេះ គឺជាលទ្ធផលនៃសមាសធាតុចុងក្រោយឬល្បាយ ដែលត្រូវបានធ្វើការបោះបង់ចោលដោយអនុវត្តតាមការប្រតិបត្តិនៅក្នុងវគ្គ "ក" នេះ ។

$D_9$ ការធ្វើប្រព្រឹត្តិកម្មតាមលក្ខណៈរូបនិងគីមី ដែលមិនមិនបញ្ជាក់អោយបានច្បាស់ ឬល្បាយដែលត្រូវបានបោះបង់ចោល ដោយអនុវត្តតាមការប្រតិបត្តិ នៅក្នុងវគ្គ " ក "នេះ ដូចជា (រំហួត សំងួត ការដុតឱ្យក្លាយជាផេះ ការបន្សាបឬការកំណក )

$D_{10}$ ការដុតសំណល់នៅលើដី

$D_{11}$ ការដុតសំណល់នៅសមុទ្រ

$D_{12}$ ការស្តុកទុកជាអចិន្ត្រៃយ៍ (ទីតាំងរបស់កុងតឺន័រនៅក្នុងទឹក )

$D_{13}$ ការលាយឬការប្រមូលចូលគ្នានៃប្រភេទសំនល់ មុននឹងដាក់ស្នើចំពោះដំណើរការប្រតិបត្តិ ដូចមានចែងក្នុង វគ្គ " ក "

$D_{14}$ ការវេចខ្ចប់ឡើងវិញ មុននឹងដាក់ស្នើចំពោះដំណើរការប្រតិបត្តិ ដូចមានចែងក្នុងវគ្គ "ក "

$D_{15}$ ការស្តុកទុកដើម្បីរង់ចាំ ដំណើរការប្រតិបត្តិ ដូចមានចែងក្នុងវគ្គ " ក "

**ខ. ដំណើរការដែលអាចឈានទៅរកការប្រើប្រាស់ធនធានឡើងវិញ ការកែច្នៃ ការចំរាញ់ ការប្រើប្រាស់ឡើងវិញដោយផ្ទាល់ ឬការប្រើប្រាស់ជំនួស**

វគ្គ ខ រួមបញ្ចូលដំណើរការចាក់ចោលសំណល់ទាំងអស់ ដែលផ្ទុកដោយវត្ថុធាតុដូចបានកំណត់តាមច្បាប់ ឬបានពិចារណាថាជាសំណល់គ្រោះថ្នាក់ បើមិនដូច្នោះទេ នឹងត្រូវអនុវត្តតាមដំណើរការប្រតិបត្តិដូចមានចែងក្នុងវគ្គ "ក "។

$R_1$ ប្រើប្រាស់ដូចប្រេងឥន្ធនៈ (ក្រៅពីការដុតផ្ទាល់) ឬប្រើប្រាស់សំរាប់បង្កើតអគ្គិសនី

$R_2$ ការទាញយក ឬបង្កើតឡើងវិញសារធាតុរំលាយ

$R_3$ ការកែច្នៃឬការទាញយកមកវិញសារធាតុសរីរាង្គ ដែលមិនប្រើជាសារធាតុរំលាយ

$R_4$ ការកែច្នៃឬការទាញយកមកវិញនូវលោហៈ និងសមាសធាតុរបស់លោហៈ

$R_5$ ការកែច្នៃឬការទាញយកមកវិញអង្គធាតុអសរីរាង្គផ្សេងៗ

$R_6$ ការបង្កើតឡើងវិញនូវអាស៊ីតឬបាស

$R_7$ ការបង្កើតឡើងវិញសមាភាគប្រើប្រាស់សំរាប់កាត់បន្ថយការបំពុល

$R_8$ ការបង្កើតឡើងវិញសមាភាគពីកាតាលីករ

$R_9$ ការប្រើប្រាស់ប្រេងដែលចំរាញ់ឡើងវិញឬការប្រើប្រាស់សារជាថ្មីនូវប្រេងដែលធ្លាប់ប្រើរួចហើយ ។

$R_{10}$ ការធ្វើប្រព្រឹត្តិកម្មដីដែលផ្តល់ផលប្រយោជន៍ដល់កសិកម្ម និងការលើកកំកើងប្រព័ន្ធអេកូឡូស៊ី

$R_{11}$ ការប្រើប្រាស់វត្ថុធាតុដែលជាសំណល់បានមកពីដំណើរការចាក់ចោល ដូចមានចែងក្នុង $R_1$ - $R_{10}$

$R_{12}$ ការផ្លាស់ប្តូរប្រភេទសំណល់ដើម្បីដាក់ស្នើចំពោះដំណើរការដូចមានក្នុង $R_1$- $R_{11}$

$R_{13}$ ការប្រមូលផ្តុំវត្ថុធាតុ ដែលចាំបាច់សំរាប់ដំណើរការក្នុងវគ្គ " ខ "

## ឧបសម្ព័ន្ធទី ៥ " ក "

## ពត៌មានដែលត្រូវផ្តល់ក្នុងប្រកាស

១- មូលហេតុនៃការនាំសំណល់ចេញ
២- ម្ចាស់នាំសំណល់ចេញ -១
៣- ម្ចាស់បង្កើតសំណល់ និងទីកន្លែងបង្កើតសំណល់ -១
៤- ម្ចាស់បោះបង់សំណល់ចោល និងទីកន្លែងពិតប្រាកដសំរាប់បោះបង់ចោល -១
៥- អ្នកដែលមានបំណងដឹកជញ្ជូនសំណល់ ឬភ្នាក់ងាររបស់គេ បើស្គាល់ -១
៦- ប្រទេសនាំសំណល់ចេញ អាជ្ញាធរមានសមត្ថកិច្ច -២
៧- ប្រទេសដែលត្រូវធ្វើការដឹកជញ្ជូនឆ្លងកាត់ អាជ្ញាធរមានសមត្ថកិច្ច -២
៨- ប្រទេសនាំចូលសំណល់ អាជ្ញាធរមានសមត្ថកិច្ច -២
៩- សេចក្តីប្រកាសទូទៅ ឬលាក់ការ
១០- ថ្ងៃខែនៃគំរោងវេចខ្ចប់ដឹកជញ្ជូន និងក្នុងកំឡុងពេលដែលសំណល់ត្រូវបាននាំចេញ និងសំណើលើគំរោងនៃការធ្វើដំណើរ (រួមទាំងចំនុចចេញ និងចូល ) -៣
១១- មធ្យោបាយដឹកជញ្ជូនដែលបានគ្រោងទុក (តាមផ្លូវថ្នល់ រថភ្លើង តាមសមុទ្រ តាមអាកាស តាមផ្លូវទឹកឆ្ងាយពីមាត់សមុទ្រ )
១២- ពត៌មានដែលទាក់ទងទៅនឹងការធានារ៉ាប់រង -៤
១៣- រៀបរាប់នាមកត្តា និងរូបនិយមនៃសំណល់ រួមទាំងលេខសំគាល់ Y លេខសំគាល់របស់ UN និងសមាសភាពរបស់វា -៥ និងពត៌មានពីការប្រើឧបករណ៍ពិសេស រួមទាំងសេចក្តីថែងអំពី ភាពអាសន្នក្នុងករណីមានគ្រោះថ្នាក់ ។
១៤- ប្រភេទនៃការវេចខ្ចប់ឡើងវិញដែលបានគ្រោងទុក (ធុង អាង ឬនាវា )
១៥- ការកំណត់បរិមាណគិតជា ទំងន់ ឬជាមាឌ -៦
១៦- រៀបរាប់ពីដំណើរនៃការផលិតសំណល់ -៧
១៧- សំណល់ដែលចុះបញ្ជីក្នុងឧបសម្ព័ន្ធ I ចំណាត់ថ្នាក់ពីឧបសម្ព័ន្ធ III អំពីលក្ខណៈនៃកំរិតគ្រោះថ្នាក់របស់សំណល់ លេខសំគាល់ H និងប្រភេទថ្នាក់ទៅតាមការកំណត់របស់ UN
១៨- របមន្តនៃការបោះបង់ចោលសំណល់ ដូចមានចែងក្នុងឧបសម្ព័ន្ធ IV
១៩- ម្ចាស់បង្កើត និងម្ចាស់នាំសំណល់ចេញត្រូវរាយការណ៍ពត៌មានឱ្យបានត្រឹមត្រូវច្បាស់លាស់ ។
២០- ក្រោយពីការវាយតំលៃលើសំណល់គ្រោះថ្នាក់ ឃើញថាពុំមានការគ្រប់គ្រងតាមលក្ខណៈបច្ចេកទេសបរិស្ថាន ដោយអនុលោមទៅតាមច្បាប់បរិស្ថាន ឬបទបញ្ញត្តិរបស់ប្រទេសនាំចូល នោះអ្នកបោះបង់សំណល់ត្រូវធ្វើការជូនដំណឹងដល់អ្នកនាំចេញ ឬអ្នកបង្កើត (រួមទាំងការងារបច្ចេកទេសរបស់រោងចក្រ ) ។
២១- ពត៌មានដែលទាក់ទងនឹងការចុះកិច្ចសន្យារវាងម្ចាស់នាំចេញ និងម្ចាស់បោះបង់សំណល់ ។

## កំណត់សំគាល់

១- នាម និងគោត្តនាម និងអាស័យដ្ឋាន ទូរស័ព្ទ ឬទូរសាររបស់បុគ្គលដែលត្រូវទាក់ទង ។

២- នាម និងគោត្តនាម និងអាស័យដ្ឋាន ទូរស័ព្ទ ឬទូរសារ ។

៣- ក្នុងករណី ពុំបានដឹងនូវការបញ្ជាក់ជាទូទៅអំពីចំនួនជើង និងកាលបរិច្ឆេទនៃការដឹកជញ្ជូនតាមផ្លូវទឹក នោះចំនួនជើងដឹកជញ្ជូនដែលប្រព្រឹត្តទៅជាញឹកញាប់នឹងអាចយកជាការបាន ។

៤- ត្រូវផ្តល់ពត៌មានដែលទាក់ទងនឹងតំរូវការបានារាប់រង និងការទទួលខុសត្រូវរបស់អ្នកនាំចេញ អ្នកដឹកជញ្ជូន និងអ្នកបោះបង់ចោល ។

៥- លក្ខណៈធម្មជាតិនិងកំហាប់នៃសមាសធាតុបង្កគ្រោះថ្នាក់ខ្លាំង ក្នុងលក្ខខណ្ឌពុលឬបង្កគ្រោះថ្នាក់ ភាគច្រើនគឺបង្ហាញឡើងតាមរយៈ ការប្រើប្រាស់សំណល់ និងវិធីសាស្ត្របោះបង់ចោលដែលត្រូវស្នើឡើង ។

៦- ក្នុងករណីសេចក្តីប្រកាសទូទៅស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក នឹងតំរូវអោយមានការលើកឡើងពីបរិមាណនិងគុណភាពតាមការប៉ាន់ស្មាន សំរាប់ការដឹកជញ្ជូននិមួយៗ ។

៧- ជាការចាំបាច់ដែរត្រូវធ្វើការវាយតំលៃពីភាពគ្រោះថ្នាក់ និងកំណត់អោយបានសមរម្យលើសំណើចំពោះដំណើរការចាក់ចោលសំណល់ ។

## ឧបសម្ព័ន្ធទី ៥ " ខ "
## ពត៌មានដែលត្រូវផ្តល់ក្នុងឯកសារចល័ត

១- ម្ចាស់នាំចេញសំណល់ -១

២- ម្ចាស់បង្កើតឬទីកន្លែងបង្កើតសំណល់ -១

៣- អ្នកបោះបង់ចោលនិងទីកន្លែងពិតប្រាកដសំរាប់បោះបង់ចោលសំណល់ -១

៤- អ្នកដឹកជញ្ជូនឬភ្នាក់ងាររបស់គេ -១

៥- កម្មវត្ថុនៃសេចក្តីប្រកាសទូទៅ ឬដាច់ដោយឡែក

៦- ថ្ងៃ ខែ នៃការចាប់ផ្តើមដំណើរការដឹកជញ្ជូនឆ្លងដែន និងថ្ងៃចុះហត្ថលេខាលើបង្កាន់ដៃដោយបុគ្គលនិមួយៗ ដែលទទួលខុសត្រូវលើសំណល់នេះ ។

៧- មធ្យោបាយដឹកជញ្ជូន (តាមផ្លូវជាតិ តាមផ្លូវដែក តាមផ្លូវទឹក តាមសមុទ្រ និងតាមអាកាស ) រាប់បញ្ចូលទាំងប្រទេសនាំចេញ នាំចូល ឆ្លងកាត់ និងចំនុចចេញ ចូល ដែលបានជ្រើសរើស ។

៨- ការរៀបរាប់ជាទូទៅពីសំណល់ (ភាព្យបនិយម ឈ្មោះ និងចំណាត់ថ្នាក់ និងលេខសំគាល់ត្រឹមត្រូវតាម UN លេខសំគាល់ Y និង H ) ។

៩- ពត៌មានទៅលើតំរូវការប្រើប្រាស់ពិសេស រួមទាំងសេចក្តីថ្លែងនៃភាពអាសន្ន ក្នុងករណីមានការគ្រោះថ្នាក់ ។

១០- ប្រភេទនិងចំនួននៃការវេចខ្ចប់

១១- បរិមាណគិតជាទំងន់និងមាឌ

១២- សេចក្តីប្រកាសដោយម្ចាស់បង្កើត និងម្ចាស់នាំចេញសំណល់ជាពត៌មានត្រឹមត្រូវ ។

១៣- សេចក្តីប្រកាសដោយម្ចាស់បង្កើតនិងម្ចាស់ដឹកជញ្ជូនសំណល់ ដែលបញ្ជាក់ថាគ្មានការជំទាស់ពីអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសពាក់ព័ន្ធទាំងអស់ដែលជាគូភាគី ។

១៤- ការបញ្ជាក់ដោយម្ចាស់បោះបង់ចោលលើបង្កាន់ដៃ ស្តីពីការជ្រើសរើសមធ្យោបាយសំរាប់ធ្វើការបោះបង់ចោល និងការគួសបញ្ជាក់ពីវិធីសាស្រ្ត និងកាលបរិច្ឆេទសមរម្យនៃការបោះបង់ចោលសំណល់នេះ ។

**កំណត់សំគាល់**

តាមច្បាប់ដឹកជញ្ជូន តំរូវការពត៌មានក្នុងឯកសារចល័ត នឹងត្រូវដាក់បញ្ចូលក្នុងឯកសារតែមួយ ។ នៅពេលដែលពត៌មានមិនអាចបញ្ចូលក្នុងឯកសារតែមួយបាន នោះច្បាប់ដឹកជញ្ជូនតំរូវអោយធ្វើការបំពេញពត៌មានដែលមានលក្ខណះប្រសើរជាងការថតចំលង ។ កន្លែងណាដែលអាចបញ្ចូលបានជាមួយតំរូវការនោះតាមច្បាប់នៃការដឹកជញ្ជូន ។ ឯកសារចល័តនឹងត្រូវអនុវត្តតាមសេចក្តី ណែនាំទៅដល់អ្នកដែលផ្តល់ពត៌មាន និងបំពេញទៅតាមពាក្យសុំ ។

១- នាមនិងគោត្តនាម និងអាស័យដ្ឋាន លេខទូរស័ព្ទនិងទូរសារបស់បុគ្គល ដែលត្រូវទាក់ទងនៅក្នុងករណីបន្ទាន់ ។

**ឧបសម្ព័ន្ធទី ៦**

**ការកាត់សេចក្តី**

**មាត្រាទី ១**

លើកលែងតែកិច្ចព្រមព្រៀងដែលបានចែងនៅក្នុងមាត្រាទី ២០ របស់អនុសញ្ញាចេញ បើមិនដូច្នេះទេ បែបបទនៃការកាត់សេចក្តី នឹងត្រូវអនុវត្តទៅតាមមាត្រាទី ២ ដល់មាត្រាទី ១០ ដូចដែលបានចែងខាងក្រោមខាងក្រោម។

**មាត្រាទី ២**

ភាគីទាមទារត្រូវប្រកាសដល់លេខាធិការដ្ឋាន អំពីគូភាគីដែលបានព្រមព្រៀង ដាក់ស្នើជំលោះនេះដើម្បីឱ្យមានការកាត់សេចក្តី ដោយអនុលោមតាមវគ្គទី ២ និងវគ្គទី ៣ នៃមាត្រាទី ២០ ជាពិសេសការបកស្រាយ ការអនុវត្តន៍មាត្រារបស់អនុសញ្ញាដូចដែលបានចែង ។ លេខាធិការដ្ឋានត្រូវបញ្ជូនពត៌មានដែលទទួលបាន ទៅកាន់ភាគីទាំងអស់ ។

## មាត្រានី ៣

ក្រុមប្រឹក្សាចៅក្រម ត្រូវមានសមាជិកចំនួនបីរូប ។ រាល់ភាគីជាគូជំលោះនឹងត្រូវជ្រើសរើសចៅក្រមមួយរូបនិងចៅក្រមចំនួនពីរូបទៀតទៅតាមការកំណត់ដោយមានការ ឯកភាព្យម ។ ចៅក្រមទី ៣ នឹងក្លាយជាប្រធានក្រុមប្រឹក្សាចៅក្រម ។ ចៅក្រមចុងក្រោយមិនអាច មានសញ្ជាតិដូចភាគីជំលោះ ឬមិនមានកន្លែងស្នាក់នៅក្នុងប្រទេសនៃគូភាគីជំលោះ ឬមិនមែនជាអ្នកធ្វើការឱ្យពួកគេពីមុន ឬគ្មានការទាក់ទងពីបញ្ហាតំណែងផ្សេងៗជាមួយពួកគេ ។

## មាត្រានី ៤

១- បើប្រធានក្រុមប្រឹក្សាចៅក្រម មិនទាន់បានកំណត់ទុកជាមុនក្នុងរយៈពេល ២ខែ មុនពេលតែងតាំងចៅក្រមទីពីរ នោះអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ នឹងត្រូវតែងតាំងក្នុងកំឡុងពេល ២ខែ តាមសំណើរបស់គូភាគី ។

២- បើសិនភាគីណាមួយក្នុងចំណោមភាគីជំលោះ មិនបានតែងតាំងចៅក្រមក្នុងរយៈពេល ២ខែ បន្ទាប់ពីបានទទួលលិខិតបញ្ជាក់តាមសំណើ ភាគីផ្សេងៗអាចជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាបុគ្គលមានសិទ្ធិតែងតាំងប្រធានក្រុមប្រឹក្សាចៅក្រមក្នុងកំឡុងពេល ២ខែ ។ នៅពេលតែងតាំងរួច ប្រធានក្រុមប្រឹក្សាចៅក្រមត្រូវស្នើភាគីនីមួយៗ ដែលមិនទាន់បានតែងតាំងចៅក្រមអោយធ្វើការតែងតាំងក្នុងរយៈពេល ២ខែ ។ បន្ទាប់ពីពេលនេះ គាត់ត្រូវជូនដំណឹងដល់អគ្គលេខាធិការ អង្គការសហប្រជាជាតិពីសមាសភាពបុគ្គលដែលត្រូវបានធ្វើការតែងតាំងឱ្យបានក្នុងរយៈពេល ២ខែ ។

## មាត្រានី ៥

១- ក្រុមប្រឹក្សាចៅក្រមនឹងត្រូវផ្តល់នូវសេចក្តីសំរេចចិត្ត ដោយអនុលោមតាមច្បាប់របស់អន្តរជាតិ និងសេចក្តីចែងរបស់អនុសញ្ញា ។

២- រាល់ក្រុមប្រឹក្សាចៅក្រមដែលបានបង្កើតឡើងតាមការចែងនៃឧបសម្ព័ន្ធនេះ នឹងត្រូវយោងតាមនិតិវិធីដែលមាននៅក្នុងច្បាប់ ។

## មាត្រានី ៦

១- រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាចៅក្រមលើនិតិវិធីនិងខ្លឹមសារសំខាន់ នឹងត្រូវទទួលយកជាការបានលុះតែមានការបោះឆ្នោតគាំទ្រពីសមាជិក ។

២- ចៅក្រមអាចអនុវត្តវិធានការណ៍សមរម្យដើម្បីបង្កើតសភាពការណ៍ពិត ។ វាអាចជាសំណើរបស់គូភាគីមួយដែលបានណែនាំពីវិធានការណ៍ចាំបាច់សំរាប់ការពារជាបណ្តោះអាសន្ន ។

៣- ភាគីជំលោះត្រូវផ្តល់គ្រប់មធ្យោបាយចាំបាច់ ដើម្បីអោយដំណើរការប្តឹងតវ៉ាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព ។

៤- ការអវត្តមានឬការខកខានភាគីក្នុងជំលោះ មិនមែនជាការបង្កើតឧបសគ្គចំពោះដំណើរការប្រព្រឹត្តទៅនៃការប្តឹងតវ៉ាឡើយ ។

## មាត្រា ៧

ចៅក្រមអាចស្តាប់និងបង្កើតឡើងផ្ទាល់នូវអំណះអំណាង ដែលមានខ្លឹមសារផ្ទុយពីបញ្ហាជំលោះ។

## មាត្រា ៨

បើសិនក្រុមប្រឹក្សាចៅក្រមមិនកំណត់បញ្ហា អាស្រ័យដោយកាលៈទេសៈពិសេសណាមួយនោះ ការចំណាយលើចៅក្រម រួមទាំងការបង់ប្រាក់ទៅលើសមាជិកគេ នឹងត្រូវបានទទួលរ៉ាប់រងដោយភាគីជំលោះ ដោយចំណែកស្មើៗគ្នា ។ ចៅក្រមត្រូវរក្សាទុកនូវរាល់ការចំណាយ នឹងត្រូវផ្តល់សេចក្តីបញ្ជាក់ការចំណាយចុងក្រោយដល់គូភាគី ។

## មាត្រា ៩

ភាគីដែលមានការចាប់អារម្មណ៍ចំពោះដំណើរប្រព្រឹត្តទៅរបស់ច្បាប់ក្នុងបញ្ហាជម្លោះ ដែលអាចប្រែប្រួលដោយសេចក្តីសំរេចចិត្ត ភាគីនោះធ្វើអន្តរគមន៍ដោយមានការឯកភាពពីចៅក្រម ។

## មាត្រា ១០

១- ក្រុមប្រឹក្សាចៅក្រម នឹងត្រូវធ្វើការផ្លាស់ប្តូរក្រោយពីរយៈពេល ៥ ខែ ចាប់ពីថ្ងៃបង្កើតលើកលែងតែមានករណីចាំបាច់ដែលអាចពន្យារពេល មិនឱ្យហួសពីរយៈពេល ៥ខែ ។

២- ការសំរេចចិត្តដោយក្រុមប្រឹក្សាចៅក្រម នឹងត្រូវភ្ជាប់ដោយការបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ការសំរេចចិត្តនេះនឹងត្រូវបញ្ចប់ ហើយភាគីជម្លោះនឹងត្រូវបានកំណត់ទៅតាមច្បាប់ ។

៣- រាល់ជំលោះដែលកើតឡើងរវាងគូភាគីទាក់ទងនឹងការបកស្រាយ ឬការប្រតិបត្តិសេចក្តីសំរេច អាចដាក់ស្នើដោយគូភាគីទៅក្រុមប្រឹក្សាចៅក្រមដែលត្រូវបានតែងតាំង ឬបើសិនមានការយឺតយ៉ាវឬពុំបានដល់ដៃចៅក្រមដែលបានបង្កើតឡើង នោះត្រូវអនុវត្តទៅតាមករណីទី ១ ។